សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស
លីកាដូ

LICADHO

Cambodian League for the Promotion and Defense of Human Rights




# ម្ដាយ នៅក្នុងពន្ធនាគារ

## ផលប៉ះពាល់នៃការឃុំខ្លួនស្ត្រី និងកូនរបស់អ្នកទាំងនោះ


របាយការណ៍ចេញ
ខែឧសភា ឆ្នាំ២០១៥

# ម្ដាយ នៅក្នុងពន្ធនាគារ៖

## ផលប៉ះពាល់នៃការឃុំខ្លួនស្ត្រី និងកូនរបស់អ្នកទាំងនោះ

របាយការណ៍ចេញខែឧសភា ឆ្នាំ២០១៥


**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស  លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល។ លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅ តាមសាខាទូទាំង ១៣ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយបុគ្គលអាជ្ញាធរ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារៈ**
បុគ្គលិកលីកាដូ ធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយអាជ្ញាធរ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ចៈ**
ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារៈ**
អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំ ទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់ៈ**
ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្តាញនានាៈ**
ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើយុទ្ធនាការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិៈ**
អ្នកហ្វឹកហ្វឺន និងអ្នកទាក់ទាញមតិគាំទ្រ ធ្វើការអប់រំដល់ក្រុមគោលដៅជាក់លាក់មួយចំនួន បណ្តាញគាំទ្រកិច្ចការពារសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន និងធ្វើការតស៊ូមតិសម្រាប់ការផ្លាស់ប្តូរសង្គម និងច្បាប់ ជាមួយស្ត្រី យុវវ័យ និងកុមារ។

**ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍ៈ**
ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេត ដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារៈ (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែលៈ contact@licadho-cambodia.org
គេហទំព័រៈ www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


សេចក្តីផ្តើម ទំព័រ១

សារតា ទំព័រ២

វិធីសាស្ត្រស្រាវជ្រាវ ទំព័រ៣

កង្វះខាតព័ត៌មានមូលដ្ឋាន ទំព័រ៥

មិនមានគោលការណ៍នយោបាយដែលមានបទដ្ឋានត្រឹមត្រូវ ទំព័រ៦

ការមិនបានយកចិត្តទុកដាក់នឹងសុខុមាលភាពរបស់កុមារ ទំព័រ៧

ផលប៉ះពាល់លើកុមារ ទំព័រ៩

- ទំនាក់ទំនងម្តាយ និងកូន ៩
- ចំណងគ្រួសារផ្សេងទៀត ១០
- ការអប់រំ ១១
- ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ១១
- សុខភាព ១២
- ការរស់នៅប្រចាំថ្ងៃ និងទំនាក់ទំនងសង្គម ១២
- ផលប៉ះពាល់ជាពិសេសចំពោះភេទ ១២

សិទ្ធិក្នុងការទាក់ទងទៅគ្រួសារ ទំព័រ១៦

សិទ្ធិទទួលបានព័ត៌មាន ទំព័រ១៧

ការមិនមានជំនួយ ទំព័រ១៩

អង្គការជីវិតនៅកម្ពុជា ទំព័រ១៩

ដំណោះស្រាយរយៈពេលវែងដែលងាយស្រួលសម្រេចបាន ទំព័រ២១

ការបញ្ឈប់ការឃុំខ្លួនដែលផ្តល់ផលអាក្រក់ និងមិនចាំបាច់ ទំព័រ២២

ថែរក្សាចំណងទំនាក់ទំនងរវាងម្តាយ និងកូន ទំព័រ២៣

សេចក្តីបញ្ចប់ ទំព័រ២៦

អនុសាសន៍ ទំព័រ២៧




កុមាររស់នៅជាមួយយាយ ខែមីនា ឆ្នាំ២០១៥



កិច្ចសម្ភាសជាមួយគ្រួសារ ខែកុម្ភៈ ឆ្នាំ២០១៥

# សេចក្ដីផ្ដើម

នៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ធនធានសន្ធឹកសន្ធាប់ត្រូវបានចំណាយទៅលើ ការបង្កើតគោលការណ៍ណែនាំស្ដីពីការអនុវត្តជម្រើសដាក់ទោសដោយមិនជាប់ឃុំ ប៉ុន្តែជម្រើសផ្សេងៗនេះ គឺកម្រត្រូវបានយកមកប្រើប្រាស់ណាស់ ទោះបីជាសម្រាប់ក្រុមដែលមានសិទ្ធិជាអាទិភាព ដូចជាស្ត្រីមានផ្ទៃពោះ និងម្ដាយដែលមានកូនតូចៗនៅជាមួយក៏ដោយ។

ដូចគ្នានេះដែរ ចៅក្រមគឺតម្រូវអោយធ្វើការពិចារណាអំពីស្ថានភាពផ្ទាល់ខ្លួនរបស់ជនសង្ស័យ មុនពេលបញ្ជាឲ្យឃុំខ្លួនបណ្ដោះអាសន្ន ដែលស្ថានភាពទាំងនេះរួមមានដូចជា ជនសង្ស័យជាស្ត្រីមានផ្ទៃពោះ ឬក៏ស្ត្រីដែលមានកូនតូចៗ។ ប៉ុន្តែ នៅពេលអនុវត្តជាក់ស្តែង ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា គឺផ្ដោតស្ទើរទាំងស្រុងលើការដាក់ឃុំឃាំងជនសង្ស័យដើម្បីរង់ចាំសវនាការទៅវិញ។

ជាលទ្ធផល កុមារជាច្រើនពាន់នាក់ត្រូវបានបំបែកចេញពីម្ដាយដែលជាប់ពន្ធនាគារដោយគ្មានការចាំបាច់ ហើយផលប៉ះពាល់គឺមានភាពធ្ងន់ធ្ងរណាស់។ ក៏ប៉ុន្តែ រហូតមកដល់បច្ចុប្បន្ន មានការសិក្សាស្រាវជ្រាវតិចតួចណាស់អំពីបញ្ហានេះនៅកម្ពុជា ហើយស្ទើរតែគ្មានការពិចារណាទាល់សោះ ដើម្បីស្វែងរកវិធីសាស្ត្រកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើកុមារ។

មានធនធានតិចតួចណាស់នៅកម្ពុជា សម្រាប់ទ្រទ្រង់កុមារដែលមានឪពុកម្ដាយជាប់ពន្ធនាគារ។ ខណៈដែលមានអង្គការមិនមែនរដ្ឋាបាលមួយចំនួន ផ្ដល់ជំនួយដល់កុមាររស់នៅក្នុងពន្ធនាគារ និងកុមារដែលធ្លាប់រស់នៅក្នុងពន្ធនាគារ[១] អង្គការ លីកាដូ មើលឃើញថា មានតែអង្គការមួយគត់[២] ដែលមានកម្មវិធីជាឯកទេសមួយបង្កើតឡើង សម្រាប់ទ្រទ្រង់កូនរបស់អ្នកជាប់ពន្ធនាគារ ដែលរស់នៅក្រៅពន្ធនាគារ។

ដើម្បីឆ្លើយតបនឹងបញ្ហានេះ អង្គការ លីកាដូ បានចាប់ផ្ដើមគម្រោងស្រាវជ្រាវថ្មីមួយ នៅខែកុម្ភៈ ឆ្នាំ២០១៥ ដែលមានការជួយគាំទ្រ និងចូលរួមដោយអង្គការមិនមែនរដ្ឋាភិបាលរបស់ប្រទេសអ៊ីតាលី ឈ្មោះ "ពិភពលោកយើង (We World)"[៣] ដោយផ្ដោតទៅលើការប្រើប្រាស់ហួសហេតុនៃការដាក់ឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ និងកង្វះខាតនៃជម្រើសដាក់ទោសផ្សេងៗ សំរាប់ស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលមានកូនក្នុងបន្ទុក ដែលស្ត្រីទាំងនេះត្រូវបានជាប់ពន្ធនាគារ ដោយសារតែបទល្មើសស្រាលៗ នៅកម្ពុជា។

របាយការណ៍នេះ បង្ហាញពីការរកឃើញនៃការស្រាវជ្រាវការផ្ដល់ឧទាហរណ៍ជាក់លាក់អំពីផលប៉ះពាល់ធ្ងន់ធ្ងរ នៃភាពមិនចាំបាច់ក្នុងការដាក់ឃុំឃាំងស្ត្រីនៅក្នុងពន្ធនាគារ និងកូនរបស់អ្នកទាំងនោះ។ ការរកឃើញរបស់អង្គការ លីកាដូ បង្ហាញថា ដោយគ្រាន់តែកាត់បន្ថយចំនួនម្ដាយដែលជាប់ពន្ធនាគារ អាជ្ញាធរអាចធ្វើអោយជីវិតរបស់កុមារជាច្រើននាក់ មានភាពល្អប្រសើរឡើង។

[១] សំរាប់ឧទាហរណ៍ http://www.ilnodoonlus.org and http://www.oecbtb.org
[២] http://www.thislifecambodia.org
[៣] អង្គការ ពិភពលោកយើង គឺជាអង្គការមិនមែនរដ្ឋាភិបាលនៃប្រទេសអ៊ីតាលី ដែលជួយគាំទ្រសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជាដែលជាដៃគូ ក្នុងការអនុវត្តនូវគម្រោងនានាដែលផ្ដោតលើសិទ្ធិកុមារ ការការពារសិទ្ធិកុមារ និងកម្មវិធីសាលារៀនសម្រាប់កុមារ។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ http://weworld.it

ជាមួយនឹងការចេញផ្សាយរបាយការណ៍នេះ អង្គការ លីកាដូ មានបំណងចង់បង្កើនការយល់ដឹងអំពីស្ថានភាពរបស់កូន អ្នកជាប់ពន្ធនាគារនៅកម្ពុជា និងដើម្បីជួយរំលឹកដល់ចៅក្រម និងព្រះរាជអាជ្ញា អំពីការទទួលខុសត្រូវរបស់ខ្លួន ក្នុងការអនុវត្តអោយបានត្រឹមត្រូវទៅនឹងនីតិវិធីច្បាប់ ដើម្បីកាត់បន្ថយភាពមិនចាំបាច់ និងផលអវិជ្ជមាននៃការឃុំឃាំង។

អង្គការ លីកាដូ បានធ្វើការបញ្ចប់របាយការណ៍ជាមួយនឹងអនុសាសន៍មួយចំនួន ស្តីពីការឃាត់ខ្លួននិងការឃុំឃាំង សវនាការ និងការដាក់ទោសម្តាយ។ អង្គការ លីកាដូ ក៏បានផ្តល់អនុសាសន៍សម្រាប់ការអនុវត្តល្អបំផុត គឺនៅពេលណាដែលការដាក់ពន្ធនាគារនោះ គឺជាជម្រើសតែមួយគត់។ ក្នុងករណីនេះ អង្គការ លីកាដូ រៀបរាប់យ៉ាងពិស្តារ អំពីពេលវេលាដែលសមស្របសម្រាប់ឲ្យកុមារនៅជាមួយម្តាយ និងអំពីការធានាការពារ ដែលត្រូវតែដាក់ឲ្យអនុវត្តដើម្បីធានាពីសុវត្ថិភាព និងសុខុមាលភាពរបស់កុមារ។


កន្លែងលក់ដូរត្រូវបានបិទចាប់តាំងពីម្តាយជាប់ឃុំក្នុងពន្ធនាគារ

# សាវតា

ការសិក្សានៅទីកន្លែងផ្ទាល់សម្រាប់គំរោងថ្មីនេះ ចាប់ផ្តើមនៅចំថ្ងៃតែមួយ ដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសអំពីការបង្កើតគណៈកម្មការនៃមន្ត្រីថ្នាក់ខ្ពស់ ដើម្បីផ្តល់ការលើកលែងទោសដល់ស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលជាប់ពន្ធនាគារជាមួយនិងកូនតូចៗ។

ការវិវឌ្ឍនេះ កើតឡើងបន្ទាប់ពីការបោះពុម្ពផ្សាយរបាយ-ការណ៍របស់លីកាដូ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីអំពី "កុមារភាពនៅក្នុងពន្ធនាគារ ការចម្រើនវ័យក្នុងពន្ធនាគារកម្ពុជា៖ រឿងរ៉ាវរបស់ដារ៉ា"[៤]។ នេះគឺជាករណីសិក្សាទីពីរដែលត្រូវបានចេញផ្សាយដោយលីកាដូ ដែលបានទាក់ទាញចំណាប់អារម្មណ៍ ក្នុងការបំពេញភាពចន្លោះនៃការយល់ដឹង អំពីកុមារវ័យក្មេងរស់នៅក្នុងពន្ធនាគារកម្ពុជា។

មិនយូរប៉ុន្មាន ក្រោយពីការប្រកាសរបស់សម្តេចនាយករដ្ឋមន្ត្រី អាជ្ញាធរកម្ពុជាបានដោះលែងស្ត្រីចំនួន ២២នាក់ ពីពន្ធនាគារ ដែលក្នុងនោះមានស្ត្រីមានផ្ទៃពោះម្នាក់ និង២១នាក់ទៀត មានកូនតូចៗចំនួន២៣នាក់។ ស្ត្រី៣៧នាក់បន្ថែមទៀត ត្រូវបានដោះលែងមុនបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ឆ្នាំ២០១៥។ ក្នុងចំណោមស្ត្រីទាំងនោះ ស្ត្រី ១៦នាក់ មានផ្ទៃពោះ និងស្ត្រី ២៣នាក់ ជាប់ពន្ធនាគារជាមួយនិងកូនតូចៗចំនួន ២៤នាក់។ ក្នុងនោះស្ត្រីពី២នាក់មានផ្ទៃពោះផងនិងមានកូនតូចម្នាក់មួយផង ហើយស្ត្រីម្នាក់ទៀតមាន កូនពីរនាក់នៅជាមួយគាត់។

[៤] http://www.licadho-cambodia.org/collection/26/childhood_behind_bars_data

នៅក្នុងការវិវឌ្ឍយ៉ាងល្អនេះ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ បានទទួលភារកិច្ចក្នុងការពិភាក្សាស្វែងរកដំណោះស្រាយរយៈពេលវែង ដើម្បីធានាសុខុមាលភាពរបស់កុមារដែលមានម្តាយកំពុងប្រឈមមុខនឹងការដាក់ទោសជាប់ពន្ធនាគារ។ មន្ត្រីរដ្ឋាភិបាលក៏បានកត់សម្គាល់ផងដែរថា នឹងមានការខិតខំប្រឹងប្រែងដើម្បីពន្លឿនសវនាការ ដល់បុគ្គលទាំងអស់ដែលកំពុងជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ។

អង្គការ លីកាដូ សូមសាទរចំពោះករណីដែលកុមារមួយចំនួនត្រូវបានកាត់បន្ថយរយៈជាប់ពន្ធនាគារបន្ថែមទៀត ប៉ុន្តែ អ្នកដែលដឹកនាំការខិតខំប្រឹងប្រែងកែទំរង់ គួរប្រយ័ត្នប្រយែង ដោយផ្តោតចំណាប់អារម្មណ៍ទៅលើតុលាការ ដែលជាកន្លែងផ្តុកនូវដំណោះស្រាយរយៈពេលវែង។ ការខិតខំប្រឹងប្រែង គួរតែចំណាយទៅលើការស្វែងរកការដាក់ទោសផ្សេងៗ ក្រៅពីការដាក់ពន្ធនាគារតាំងពីដំបូងជាជាងការដោះលែងស្ត្រីមានផ្ទៃពោះ និងស្ត្រីមានកូនចេញពីពន្ធនាគារៀងរាល់ឆ្នាំ ដូច្នេះកុមារមិនចាំបាច់ត្រូវឃើញអ្វីៗនៅខាងក្នុងរបងពន្ធនាគារឡើយ។

ចំពោះបញ្ហានេះ អង្គការ លីកាដូ បានកត់សម្គាល់ថា ខណៈដែលមាននីតិវិធី និងគោលការណ៍ណែនាំមានរួចហើយនៅកម្ពុជា ដើម្បីអោយចំណុចនេះដំណើរការទៅបាន ជម្រើសផ្សេងៗ គឺកម្រត្រូវបានយកមកពិចារណាណាស់ ទោះបីជាសុខុមាលភាពរបស់ក្មេងតូចកំពុងស្ថិតតែនៅក្នុងគ្រោះថ្នាក់ក៏ដោយ។

# វិធីសាស្ត្រស្រាវជ្រាវ

អង្គការ លីកាដូ បានធ្វើការស្ទង់មតិមួយស្តីអំពីនីតិវិធីរដ្ឋបាលទាក់ទងនឹងម្តាយ និងកូនរបស់អ្នកទាំងនោះដែលរស់នៅក្នុងពន្ធនារគារចំនួន ១៤កន្លែង[៥] ដើម្បីកំណត់នូវទំហំព័ត៌មាន ថាតើពន្ធនាគារមួយណាមានព័ត៌មានអំពីកូនរបស់អ្នកទោស ទីកន្លែងស្នាក់នៅរបស់កូនក្មេងទាំងនោះ ការរៀបចំអ្នកថែទាំក្មេង និងថាតើមាននីតិវិធីពិសេសណាមួយត្រូវបានដាក់ឲ្យអនុវត្ត ដើម្បីអោយកុមារចូលទៅសួរសុខទុក្ខម្តាយនៅក្នុងពន្ធនាគារ។

អង្គការ លីកាដូ ក៏បានធ្វើបទសម្ភាសផងដែរជាមួយនឹងស្ត្រីជាម្តាយដែលកំពុងជាប់ពន្ធនាគារ ឬដែលត្រូវបានដោះលែងថ្មីៗចំនួន ៩៦នាក់ និងជាមួយអ្នកថែទាំកុមារខាងក្រៅពន្ធនាគារ ចំនួន ៣៦នាក់ នៅក្នុង ១២ខេត្ត និងនៅរាជធានីភ្នំពេញ។ ភាគច្រើននៃស្ត្រីដែលចូលរួមបទសម្ភាសទាំងនោះ គឺជាម្តាយដែលរស់នៅក្នុងពន្ធនាគារដែលត្រូវបានចោទប្រកាន់ ឬត្រូវបានរកឃើញថាមានទោសពីបទល្មើសស្រាល ឬបទល្មើសអហិង្សា ហើយពួកគាត់មានកូននៅក្នុងបន្ទុកដែលមានអាយុក្រោម ១៨ឆ្នាំ។

បទសម្ភាសត្រូវបានបង្កើតឡើងដើម្បីប្រមូលព័ត៌មាន អំពីបទពិសោធន៍នៃការឃាត់ខ្លួន និងការជាប់ឃុំឃាំងរបស់ម្តាយនិងកូន ដែលរួមទាំងការសួរសុខទុក្ខក្នុងពន្ធនាគារ ទំនាក់ទំនង និងការទទួលបានព័ត៌មានរវាងម្តាយនិងកូន និងផលប៉ះពាល់ពិសេសទៅលើកុមារ នៅពេលម្តាយរបស់កុមារត្រូវបានបញ្ជូនទៅពន្ធនាគារ។

ក្នុងចំណោមស្ត្រីចូលរួមបទសម្ភាសទាំងអស់ ស្ត្រី ៤៧នាក់ មិនទាន់ទទួលបានសវនាការជំនុំជម្រះ។ ដោយលើកលែងតែស្ត្រីជនជាតិថៃម្នាក់ ស្ត្រីចូលរួមបទសម្ភាសទាំងអស់ គឺជាជនជាតិខ្មែរ ឬអ្នកមានដើមកំណើតវៀតណាម បានតាំងទីលំនៅនៅកម្ពុជាអស់រយៈពេលយូរឆ្នាំមកហើយ។

ដើម្បីយល់ដឹងអោយច្បាស់អំពីលទ្ធផលនៃការផ្លាស់ប្តូរនៅក្នុងច្បាប់ នៅឆ្នាំ២០១១ អង្គការ លីកាដូ បានធ្វើការសម្ភាសជាមួយនឹងម្តាយជាប់នៅក្នុងពន្ធនាគារមួយចំនួន ដែលកូនរបស់អ្នកទាំងនោះត្រូវបានយកចេញពីពន្ធនាគារ ដែលជាលទ្ធផលនៃការផ្លាស់ប្តូរនេះ។

"ពេលខ្លះនៅពេលខ្ញុំមកពីសាលាវិញ អត់មានអ្វីញាំទេ សូម្បីតែបាយក៏មិនមានដែរ។ ម៉ាក់ខ្ញុំតែងតែធ្វើម្ហូបរាល់ពេល ប៉ុន្តែឥឡូវអត់មានអ្នកណារៀបចំម្ហូបទៀតទេ។"

## ស្ថិតិ

ក្នុងចំណោមម្តាយ ៩៦នាក់ ដែលចូលរួមសម្ភាស

**៧០%**

គ្មានមេធាវី

**៥៦%**

ត្រូវបានចោទប្រកាន់ ឬ កាត់ទោស ពីបទល្មើស ទាក់ទងនិងគ្រឿងញៀន

**៩៧%**

មិនដែលជាប់ពន្ធនាគារពីមុនទាល់តែសោះ

[៥] មណ្ឌលអប់រំកែប្រែទី ២ (CC2) តាខ្មៅ កំពង់សោម កំពង់ស្ពឺ កំពត កំពង់ឆ្នាំង កំពង់ចាម កំពង់ធំ ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ស្វាយរៀង និងកោះកុង។

**១០០%**

នៃអ្នកដែលជាប់ទោសត្រូវបានឃុំឃាំងជាបណ្ដោះអាសន្នមុន សវនាការ។

**៣២នាក់**

កូនមិនដែលបានមកសួរសុខទុក្ខសោះ។

**៩៤%**

នៃគ្រួសារ ត្រូវបង់ប្រាក់សំរាប់ការសួរសុខទុក្ខក្នុងពន្ធនាគារ។

ដូចគ្នានេះដែរ ជាមួយនឹងទស្សនៈដើម្បីស្វែងយល់អោយច្បាស់អំពីតម្រូវការរបស់កូនដែលម្ដាយជាប់ពន្ធនាគារ និងដើម្បីប្រៀបធៀបរវាងបទពិសោធន៍របស់អ្នកទទួលបាននិងអ្នកមិនទទួលបានជំនួយពីខាងក្រៅ អង្គការ លីកាដូ ដោយមានជំនួយពីអង្គការ ពិភពលោកយើង បានធ្វើការសម្ភាសជាមួយស្ត្រីមួយចំនួនដែលបានទទួល ឬបន្តទទួលជំនួយពីអង្គការជីវិតនៅកម្ពុជា នៅក្នុងខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ។

ដើម្បីកាត់បន្ថយការរំខានដល់ការរស់នៅប្រចាំថ្ងៃរបស់ក្រុមគ្រួសារ និងការសិក្សារបស់កុមារ អង្គការលីកាដូ មិនបានធ្វើការស្នើសុំជាពិសេសអោយកុមារចូលរួមបទសម្ភាសនោះទេ ប៉ុន្តែផ្ទុយទៅវិញ អង្គការ លីកាដូ ទុកការសម្រេចចិត្តនេះអោយទៅអ្នកថែទាំកុមារវិញ។ គោលបំណងនៃបទសម្ភាស ត្រូវបានពន្យល់យ៉ាងច្បាស់ជាមុន ហើយអ្នកចូលរួមត្រូវបានផ្ដល់នូវជម្រើសដើម្បីចូលរួម ឬមិនចូលរួម។

នៅពេលជួបជាមួយក្រុមគ្រួសាររបស់ម្ដាយដែលជាប់ពន្ធនាគារ អង្គការ លីកាដូ ជាដំបូងបានសុំនិងទទួលការយល់ព្រមពីម្ដាយ និងពិនិត្យមើលមុនពេលធ្វើការបទសម្ភាសថាតើកុមារទាំងនោះបានដឹងថាម្ដាយរបស់ពួកគេជាប់ពន្ធនាគារ និងបានដឹងពីព័ត៌មានសើបដទៃទៀត ដូចជាចរិតលក្ខណៈនៃការចោទប្រកាន់ទៅលើម្ដាយរបស់អ្នកទាំងនោះឬទេ។ នៅពេលកុមារបានបង្ហាញខ្លួន អង្គការ លីកាដូ បានចងក្រងសំណួរសម្ភាសយ៉ាងសមរម្យ និងផ្ដល់ឱកាសឲ្យកុមារ បង្ហាញពីទស្សនៈផ្ទាល់ខ្លួន និងផ្ដល់ឱកាសអោយកុមារទាំងនោះសួរ ប្រសិនបើអ្នកទាំងនោះមានចម្ងល់។

បទសម្ភាសជាមួយនឹងម្ដាយនៅក្នុងពន្ធនាគារ ត្រូវបានធ្វើឡើងក្រោមស្ថានភាពផ្សេងៗគ្នាផ្អែកតាមពន្ធនាគារនីមួយៗ។ បទសម្ភាសខ្លះត្រូវបានធ្វើឡើងនៅក្នុងបរិយាកាសឯកជន ខណៈដែលបទសម្ភាសខ្លះទៀតត្រូវបានធ្វើឡើងនៅខាងមុខរបាំងដែក និងក្នុងករណីខ្លះ អ្នកយាមមានវត្តមានអំឡុងពេលបទសម្ភាសផងដែរ។

ខណៈពេលដែល អង្គការ លីកាដូ ទទួលស្គាល់ថាកុមារតែងតែទទួលរងផលប៉ះពាល់ពីការជាប់ពន្ធនាគាររបស់សមាជិកគ្រួសារ និងអ្នកថែទាំចំបង ដូចជា ឪពុក លោកតា លោកយាយ បងប្រុសបងស្រី ឪពុកម្ដាយចុង ឬ ឪពុកម្ដាយចិញ្ចឹម ទំហំនៃការសិក្សានេះត្រូវបាន កំណត់ត្រឹមម្ដាយបង្កើតដែលជាប់ពន្ធនាគារ។ បញ្ហានេះដោយសារនៅកម្ពុជា ម្ដាយបង្កើតតែងតែជាអ្នកថែទាំចំបង ហើយនៅពេលដែលអ្នកទាំងនោះត្រូវបានបញ្ជូនទៅពន្ធនាគារ គឺតែងតែរំខានដល់ជីវិតកុមាររួមមានដូចជាការផ្លាស់ទីលំនៅ និងការសិក្សាជាដើម។

ដូចគ្នានេះដែរ ខណៈដែលលទ្ធផលស្រាវជ្រាវរបស់អង្គការ លីកាដូ បង្ហាញថាការដាក់ពន្ធនាគារម្ដាយម្នាក់ នឹងអាចធ្វើអោយប៉ះពាល់ដល់សមាជិកគ្រួសារដទៃទៀត ដូចជាសាច់ញាតិដែលមានជំងឺ ឬដែលជាចាស់ទុំ។ លទ្ធផលរកឃើញនេះត្រូវបានដាក់បញ្ចូលនៅក្នុងរបាយការណ៍នេះ ចំពោះតែករណីដែលសាច់ញាតិទាំងនោះមានទំនាក់ទំនងផ្ទាល់ជាមួយនឹងកូនរបស់ស្ត្រីដែលជាប់ពន្ធនាគារប៉ុណ្ណោះ។



កូនស្រីរបស់អ្នកជាប់ពន្ធនាគារជាស្ត្រី ខែកុម្ភៈ ឆ្នាំ២០១៥

# កង្វះខាតព័ត៌មានមូលដ្ឋាន

វិធាននៃសហប្រជាជាតិសម្រាប់ថែទាំអ្នកជាប់ពន្ធនាគារជាស្ត្រី និងវិធានការមិនឃុំខ្លួនសម្រាប់ជនល្មើសជាស្ត្រី (វិធានក្រុងបាងកក)[៦] ចែងថា នៅពេលដែលស្ត្រីម្នាក់ត្រូវបានដាក់នៅក្នុងពន្ធនាគារ គួរតែកត់ត្រាទុកនូវចំនួន និងព័ត៌មានផ្ទាល់ខ្លួននៃកូនរបស់គាត់ ដែលក្នុងនោះរួមមានឈ្មោះនិងអាយុរបស់កូន ហើយប្រសិនបើជាកូនមិនទៅតាមម្តាយទៅក្នុងពន្ធនាគារ គួរតែកត់ត្រាពីទីកន្លែង និងសិទ្ធិធ្វើអាណាព្យាបាល ឬស្ថានភាពនៃអាណាព្យាបាលនោះ។[៧]

ការសិក្សារបស់អង្គការ លីកាដូ បានបង្ហាញអោយឃើញថា នៅក្នុងប្រទេសកម្ពុជា ពន្ធនាគារភាគច្រើនដែលត្រូវបានធ្វើការស្រាវជ្រាវ មិនមានព័ត៌មានបែបនេះនោះទេ និងនីតិវិធីនៃការចុះបញ្ជីចូលរបស់អ្នកជាប់ពន្ធនាគារ ចាប់តាំងពីឆ្នាំ ២០០៣មក មិនតម្រូវឲ្យធ្វើការកត់ត្រាព័ត៌មានទាំងនេះ នៅក្នុងបញ្ជីផ្លូវការនៃអ្នកជាប់ពន្ធនាគារនោះឡើយ។[៨] ជាការពិត មានពន្ធនាគារតែមួយគត់ដែលមានព័ត៌មានជាក់លាក់អំពីកូនរបស់អ្នកជាប់ពន្ធនាគារ ដែលក្នុងនោះរួមមានអាយុ និងទីកន្លែងស្នាក់នៅបច្ចុប្បន្នរបស់កូន។

អង្គការ លីកាដូ ជឿជាក់ថា ការកត់ត្រាព័ត៌មានបែបនេះគឺមានសារៈសំខាន់សម្រាប់ធានាថា ម្តាយម្នាក់អាចរក្សាការទាក់ទងជាមួយនិងកូនរបស់នាងបាន និងបន្តទទួលបានព័ត៌មានអំពីសុខុមាលភាពរបស់កូន និងការប្រែប្រួលនៃស្ថានភាពក្រុមគ្រួសារ។ម្យ៉ាងទៀត ការកត់ត្រាព័ត៌មានបែបនេះ ក៏គួរតែអនុញ្ញាតអោយកុមារ និងអ្នកមើលថែកុមារបន្តទទួលបានព័ត៌មានដែលកើតឡើង ទាក់ទងទៅនឹងការជាប់ពន្ធនាគាររបស់ម្តាយ ដូចជាការសម្រេចចិត្តផ្លូវច្បាប់សំខាន់ៗ បញ្ហាសុខភាព ឬការផ្លាស់ទីតាំងនៅក្នុងពន្ធនាគារ ឬទៅពន្ធនាគារមួយទៀត។

ព័ត៌មានរដ្ឋបាលបែបនេះ ក៏មានសារៈសំខាន់ផងដែរសំរាប់ការរៀបចំមុនពេលនឹងដោះលែងអ្នកជាប់ពន្ធនាគារ ដើម្បីអោយសមាជិកគ្រួសារដែលសមស្របបំផុត អាចទទួលបានព័ត៌មានមុនកាលបរិច្ឆេទនៃការដោះលែង និងធ្វើការចាត់ចែង និងរៀបចំអោយកូនៗទទួលម្តាយរបស់ពួកគេត្រលប់ទៅផ្ទះវិញ។

[៦] http://www.un.org/en/ecosoc/docs/2010/res%202010-16.pdf ត្រូវបានអនុម័តដោយមហាសន្និបាត អង្គការសហប្រជាជាតិ ក្នុងខែធ្នូ ឆ្នាំ២០១០។
[៧] ស្ត្រីគួរតែមិនត្រូវបានបង្ខំអោយបើកចំហរពីព័ត៌មាននេះប្រសិនបើគាត់មិនចង់ធ្វើ។
[៨] និតិវិធីពន្ធនាគារ ១៖ ការចុះបញ្ជីចូលក្នុងពន្ធនាគារ

អង្គការ លីកាដូ ទទួលស្គាល់ថា អាចមានការពិបាកសំរាប់ពន្ធនាគារក្នុងការរក្សាទុកព័ត៌មានជាក់លាក់ អំពីស្ថានភាពក្រុមគ្រួសារ ប្រសិនបើពួកគេមិនបានទទួលព័ត៌មានត្រឹមត្រូវពីមន្ត្រីតុលាការ។ អង្គការ លីកាដូ ក៏ទទួលស្គាល់ផងដែរថា អាចមានការពិបាកក្នុងការធ្វើបច្ចុប្បន្នភាពព័ត៌មានថ្មីបំផុត ដោយមិនមានសហប្រតិបត្តិការពីក្រុមគ្រួសារអ្នកជាប់ពន្ធនាគារ។ ដូច្នេះ ខណៈពេលដែលអាជ្ញាធរពន្ធនាគារ គួរតែធ្វើការខិតខំប្រឹងប្រែងធ្វើអ្វីដែលអាចធ្វើបាន ដើម្បីរក្សាទុក និងរក្សាព័ត៌មានឲ្យបានត្រឹមត្រូវ ក្រុមគ្រួសារអ្នកជាប់ពន្ធនាគារក៏ត្រូវតែទទួលការខុសត្រូវ ក្នុងការធានាថាពន្ធនាគារទទួលបានព័ត៌មានពីការផ្លាស់ប្តូររបស់ក្រុមគ្រួសារផងដែរ។

# មិនមានគោលនយោបាយដែលមានបទដ្ឋានត្រឹមត្រូវ

ខណៈពេលដែលជាភ័ព្វសំណាងសំរាប់អ្នកជាប់ពន្ធនាគារដែលត្រូវបានដោះលែងដោយសារកូនរបស់អ្នកទាំងនោះរស់នៅក្នុងពន្ធនាគារជាមួយ និងសំរាប់អ្នកជាប់ពន្ធនាគារដែលសវនាការត្រូវបានពន្លឿនដោយសារមូលហេតុដូចគ្នា ប៉ុន្តែការលើកលែងទោសធ្វើឡើងថ្មីៗនេះបានបង្ហាញនូវភាពខ្វះចន្លោះសំខាន់ៗមួយចំនួន នៅក្នុងនីតិវិធីដែលកំណត់ថាតើឲ្យកុមាររស់នៅជាមួយម្តាយក្នុងពន្ធនាគារ ឬក៏មិនត្រូវឲ្យកុមារនៅក្នុងពន្ធនាគារជាមួយម្តាយ។

បច្ចុប្បន្ននេះ ហាក់បីដូចជា មិនទាន់មាននីតិវិធីត្រឹមត្រូវណាមួយត្រូវបានដាក់ឲ្យអនុវត្ត ដើម្បីកំណត់ថានៅពេលណា និងមូលហេតុអ្វីដែលកុមារតូចម្នាក់នឹងអាចរស់នៅក្នុងពន្ធនាគារជាមួយម្តាយរបស់គាត់នោះទេ។ ផ្ទុយទៅវិញ ដំណើរនៃហេតុការណ៍និងការសម្រេចចិត្តដែលឲ្យកុមារម្នាក់រស់នៅជាមួយម្តាយនៅក្នុងពន្ធនាគារ គឺមិនមានលក្ខណៈច្បាស់លាស់ ហើយដោយផ្អែកតាមការដោះលែងថ្មីៗនេះ មូលហេតុទាំងនេះ គឺមិនទាន់សមរម្យទេ។ ទីតាំងភូមិសាស្ត្រ និងវត្តមានរបស់មនុស្សពេញវ័យនៅពេលឃាត់ខ្លួន អត្តសញ្ញាណរបស់អាជ្ញាធរដែលធ្វើការចាប់ខ្លួន និងគោលនយោបាយរបស់ពន្ធនាគារនីមួយៗ គឺជាកត្តាសម្រេចចិត្តដ៏សំខាន់ ដែលតែងតែមានអាទិភាពលើការចង់បានរបស់ម្តាយ ហើយសំខាន់ជាងនេះ គឺការធ្វើតាមទម្លាប់ពីមុន ច្រើនជាងធ្វើការពិចារណាអំពីឧត្តមប្រយោជន៍របស់កុមារ។



កូនតូចរស់នៅជាមួយអនាព្យាបាល ខែមីនា ឆ្នាំ២០១៥

ស្ត្រីមួយចំនួន ដែលត្រូវបានសម្ភាសដោយអង្គការ លីកាដូ បានឲ្យដឹងថា កូនរបស់ពួកគាត់ ស្នាក់នៅជាមួយ ដោយសារមូលហេតុសាមញ្ញ គឺអ្នកទាំងនោះកំពុងនៅជាមួយគ្នា នៅពេលគេឃាត់ខ្លួន និងមិនមានវត្តមានអ្នកណាម្នាក់ ដែលអាចមើលថែកូនទាំងនោះ នៅក្រៅពន្ធនាគារបានភ្លាមៗនោះទេ។ អ្នកដទៃទៀត បានរាយការណ៍ថា នគរបាលហាមឃាត់យ៉ាងសកម្ម មិនអោយអ្នកទាំងនោះនាំកូនទៅប៉ុស្តិ៍នគរបាលជាមួយទេ ទោះបីជាមិនមានជម្រើសផ្សេងៗដើម្បីមើលថែកូននោះក៏ដោយ។ នៅក្នុងពន្ធនាគារមួយចំនួនកុមារត្រូវបាន អនុញ្ញាតអោយទៅរស់នៅជាមួយម្តាយនៅក្នុងពន្ធនាគារ បន្ទាប់ពីបានសំណូមពរទៅអាជ្ញាធរ ពន្ធនាគារ។ នៅក្នុងពន្ធនាគារដទៃទៀត អាជ្ញាធរបានបដិសេធសំណូមពរបែបនេះ។

ភាពខុសគ្នានៃការដោះស្រាយករណីទាំងនេះ ពន្យល់ពីមូលហេតុដែលម្តាយមួយចំនួនអាចទុកកូនឲ្យនៅក្នុងពន្ធនាគារបាន និងម្តាយខ្លះទៀតមិនអាចធ្វើបាន។ អង្គការ លីកាដូ ក៏បានកត់សម្គាល់ផងដែរថា ស្ត្រីមួយចំនួនដែលបានសម្រេចចិត្តស្វែងរកការរៀបចំមើលថែកូននៅខាងក្រៅពន្ធនាគារ ដោយមិនដឹងខ្លួនថាការធ្វើបែបនេះធ្វើអោយអន្តរាយដល់ឱកាសទទួលបានការដោះលែងមុនកំណត់ ឬការពន្លឿនសវនាការនោះទេ។

## ករណីសិក្សា៖ សាសា

សាសាមានកូនពីរនាក់ គឺកូនប្រុសអាយុ ៥ឆ្នាំម្នាក់ និងកូនស្រីម្នាក់មានអាយុត្រឹមតែ ៦ខែ នៅពេលដែលសាសាត្រូវបានបញ្ជូនទៅពន្ធនាគារ។ សាសា ត្រូវបានឃាត់ខ្លួន ខណៈពេលដែលនាងកំពុងដើរតាមដងផ្លូវបីកូនស្រី ហើយដោយសារតែកូនស្រីនាងកំពុងតែនៅត្រូវការបំបៅដោះនៅឡើយ សាសាបាននាំយកកូនស្រីទៅទីស្នាក់ការនគរបាល ជាមួយគ្នា។

នៅពេលស្វាមីរបស់សាសាមកសួរសុខទុក្ខនាង នៅទីស្នាក់នគរបាលនៅថ្ងៃដដែលនោះ មន្ត្រីនគរបាលបានអោយកូនស្រីទៅគាត់ និងប្រាប់គាត់អោយយកកូនទៅផ្ទះ។ សាសាមិនទទួលបានជម្រើសក្នុងការទុកកូនរបស់នាងទេ ហើយនៅពេលក្រោយមក នៅក្នុងពន្ធនាគារ នាងបានសាកសួរថា តើកូនរបស់នាង អាចមកនៅជាមួយនាងបានដែរឬទេ ប៉ុន្តែ គេប្រាប់នាងថារឿងនេះមិនអាចធ្វើបាននោះទេ។

ពីផ្ទះគ្រួសាររបស់សាសា មកពន្ធនាគារ ត្រូវការចំណាយពេលធ្វើដំណើរពីរម៉ោង ហើយកូនរបស់នាងបានទៅសួរសុខទុក្ខនាងពីរ ឬ បីដង ក្នុងអំឡុងពេលជាប់ពន្ធនាគារមួយឆ្នាំរបស់នាង។ ពួកគេបានជួបគ្នានៅក្នុងបរិវេណជួបគ្នារួម ប៉ុន្តែមិនដែលទទួលបានពេលវេលាឯកជនជាមួយគ្នានោះទេ។

សាសាត្រូវបានឃាត់ខ្លួន នៅខែមេសា ឆ្នាំ២០១៤ ពីការសង្ស័យ អំពើចោរកម្ម និងត្រូវបានឃុំឃាំងរយៈពេលដប់ខែ មុនពេលទទួលបានសវនាការ និងផ្តន្ទាទោសអោយជាប់ពន្ធនាគារមួយឆ្នាំ។ នាងត្រូវបានដោះលែងបួនថ្ងៃក្រោយបន្ទាប់ពីអង្គការ លីកាដូ បានសម្ភាសនាង។

# ការមិនបានយកចិត្តទុកដាក់នឹងសុខុមាលភាពរបស់កុមារ

នៅពេលណាដែលមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការត្រូវដោះស្រាយបញ្ហាពាក់ព័ន្ធនឹងកុមារក្នុងនាមជាអ្នកជំនាញ អ្នកទាំងនោះគួរតែអនុវត្តដោយយកចិត្តទុកដាក់ ប្រុងប្រយ័ត្ន ហើយជាពិសេសយកចិត្តទុកដាក់ចំពោះអាយុ តម្រូវការ និងភាពងាយរងគ្រោះជាក់លាក់របស់កុមារ ដោះស្រាយបញ្ហាទាំងនេះដោយមធ្យោបាយសមរម្យ។

នៅពេលដែល អង្គការ លីកាដូ មិនបានកត់ត្រាករណីនានានៃអំពើហិង្សារបស់នគរបាល ទៅលើស្ត្រីនៅចំពោះមុខកូនរបស់អ្នកទាំងនោះ នៅក្នុងករណីភាគច្រើននៅពេលដែលកុមារមានវត្តមាននៅពេលឃាត់ខ្លួនម្តាយ អាជ្ញាធរធ្វើហាក់ដូចជាកុមារមិននៅទីនោះ និងចាប់ម្តាយរបស់អ្នកទាំងនោះ ដោយមិនមានការបកស្រាយពន្យល់អ្វីឡើយ។ ការធ្វើបែបនេះតែងតែធ្វើអោយកុមារពិបាកចិត្ត ភ័យខ្លាច និងយល់ច្រឡំ។ កុមារមួយចំនួនបានរត់ ឬពួននៅពេលឃើញនគរបាល និងកុមារខ្លះទៀត ត្រូវបានទុកចោលដោយគ្មានអ្នកណាមើលថែ។

នៅពេលឃាត់ខ្លួន ជាទូទៅនគរបាលហាក់បីដូចជាមិនយកចិត្តទុកដាក់ពីស្ថានភាពគ្រួសារ និងសុខុមាលភាពរបស់កុមារណាមួយ ដែលនៅក្នុងបន្ទុកក្រុមគ្រួសារនោះទេ។ ប្រសិនបើមិនមានវត្តមានកូននៅពេលឃាត់ខ្លួន នគរបាលជាញឹកញាប់មិនដែលសួរថាតើ មានកូននៅក្នុងក្រុមគ្រួសារនោះដែរឬទេ។ ដូចគ្នាដែរ ប្រសិនបើកូនម្នាក់ ឬ ច្រើននាក់មានវត្តមាននៅទីនោះ នគរបាលទាំងនោះជាទូទៅមិនបានសួរថាតើមានកូនផ្សេងទៀតដែរឬទេនោះទេ។ ទោះបីជានៅក្នុងករណីមួយចំនួនដែលនគរបាលសួរអំពីចំនួន និងអាយុរបស់កូន អ្នកទាំងនោះជាធម្មតាមិនយកចិត្តទុកដាក់ពីអ្វីខ្លះដែល អាចប៉ះពាល់ដល់កូននៅពេលម្តាយអវត្តមាន ទោះបីជានគរបាលទាំងនោះបានដឹងថា មិនមានមនុស្សពេញវ័យណាមួយអាចទទួលខុសត្រូវមើលកុមារបានភ្លាមៗនោះក៏ដោយ។

អង្គការ លីកាដូ បានកត់ត្រាករណីដែលនគរបាលទុកកុមារអោយនៅជាមួយជនមិនស្គាល់ ឬមនុស្សពេញវ័យដែលកុមារមានទំនាក់ទំនងតិចតួចជាមួយ។ កុមារមួយចំនួនត្រូវបានទុកអោយនៅដោយខ្លួនឯងដោយមិនមានការរៀបចំការមើលថែណាមួយទេ ហើយមិនមានការព្យាយាមណាមួយ ដើម្បីផ្តល់ដំណឹងដល់សមាជិកក្រុមគ្រួសារអំពីការឃាត់ខ្លួនរបស់ម្តាយនោះដែរ។ ពេលខ្លះ មានការសន្មត់ថាបងប្រុសបងស្រីដែលត្រឹមតែជាកុមារនៅឡើយ ជាអ្នកទទួលខុសត្រូវមើលថែទាំ ប្អូនស្រី ឬប្អូនប្រុសរបស់អ្នកទាំងនោះ។

នៅពេលដែលស្ត្រីត្រូវបានហៅ ទៅទីស្នាក់ការនគរបាលដើម្បីសួរចម្លើយមុនពេលឃាត់ខ្លួន ពួកគាត់ជាញឹកញាប់មិនបានដឹងថាពួកគាត់នឹងត្រូវជាប់ឃុំឃាំង ហើយដូច្នេះអ្នកទាំងនោះមិនបានពិចារណារៀបចំការមើលថែកូនរយៈពេលខ្លី ឬរយៈពេលវែងនោះទេ។ ពេលខ្លះអ្នកទាំងនោះទុកកូនអោយនៅម្នាក់ឯង ដោយស្មានថាពួកគាត់នឹងទៅត្រឹមតែរយៈពេលខ្លីប៉ុណ្ណោះនឹងត្រលប់មកវិញ។

កង្វះខាតឱកាសសម្រាប់ម្តាយ ដើម្បីរៀបចំការមើលថែកូនអោយសមរម្យបន្ទាប់ពីការឃាត់ខ្លួនរបស់ពួកគាត់ ត្រូវបានរកឃើញនៅក្នុងករណីជាច្រើន ដោយស្ត្រីមួយចំនួនបានប្រាប់អង្គការ លីកាដូ ថា ពួកគាត់មិនត្រូវបានអនុញ្ញាតអោយទូរស័ព្ទពីទីស្នាក់នគរបាលទៅក្រុមគ្រួសារនោះទេ ទោះបីជាកូនរបស់គាត់ត្រូវបានទុកចោលដោយគ្មានអ្នកមើលថែ ឬទុកនៅជាមួយអ្នកមិនជាប់សាច់ញាតិក៏ដោយ។

ស្ត្រីមួយចំនួនបានប្រាប់អង្គការ លីកាដូ ថា នគរបាលមិនបានសាកសួរអំពីស្ថានភាពក្រុមគ្រួសាររបស់អ្នកទាំងនោះទេ ប៉ុន្តែនេះប្រហែលដោយសារអាជ្ញាធរមូលដ្ឋានដឹងពីសមាជិកគ្រួសារ និងអ្នកដែលអាចនឹងថែទាំកុមារនៅពេលស្ត្រីទាំងនោះអវត្តមាន។ នៅក្នុងទស្សនៈរបស់អង្គការ លីកាដូ វិធីសាស្ត្របែបនេះគឺគ្មានការទទួលខុសត្រូវទាំងស្រុង ដោយសារមិនបានគិតដល់ធម្មជាតិនៃការផ្លាស់ប្តូរទំនាក់ទំនងក្រុមគ្រួសារ និងការខ្វះខាតការទទួលព័ត៌មានរបស់អាជ្ញាធរ អំពីការប្រែប្រួលក្នុងក្រុមគ្រួសារ និងផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើងលើកុមារ។

លទ្ធផលដែលអង្គការ លីកាដូ បានរកឃើញ បង្ហាញអោយឃើញថា សុខុមាលភាពរបស់កុមារមិនត្រូវបានយកចិត្តទុកដាក់នៅពេលឃាត់ខ្លួន និងរហូតដល់នីតិវិធីតុលាការបានបញ្ចប់។ ស្ត្រីជាច្រើននាក់ដែលត្រូវបានសម្ភាសដោយអង្គការ លីកាដូ បាននិយាយថាអ្នកទាំងនោះមិនដែលទទួលបានការសាកសួរ អំពីស្ថានភាពក្រុមគ្រួសាររបស់គាត់ នៅពេលមានការចេញដីកាឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ឬនៅអំឡុងពេលសវនាការ និងពេលផ្តន្ទាទោសនោះទេ។ ចំពោះអ្នកដែលទទួលបានការសាកសួរ មានតែស្ត្រីពីរទៅបីនាក់ប៉ុណ្ណោះដែលទទួលបានការសាកសួរអំពីទីកន្លែងកូនស្នាក់នៅ និងការរៀបចំមើលថែ។ គួរអោយសោកស្តាយ ផលលំបាកទាំងនេះក៏កើតឡើងដូចគ្នាទៅលើករណីរបស់ស្ត្រីមួយចំនួន ដែលមានមេធាវីការពារក្តី ដោយស្ត្រីទាំងនោះបានរាយការណ៍ថា សូម្បីតែមេធាវីរបស់ពួកគាត់ក៏មិនបានសួរពួកគាត់ថាតើ គាត់មានកូនដែរឬទេ នោះដែរ។

## ករណីសិក្សា៖ ផល្លា

អំឡុងពេលឃាត់ខ្លួន ផល្លា កំពុងនៅផ្ទះជាមួយនឹងកូនប្រុសអាយុ ៩ឆ្នាំ និងចៅប្រុសអាយុ ៧ឆ្នាំ ជាមួយនិងម្ដាយរបស់ចៅ ដែលត្រូវជាកូនស្រីរបស់គាត់ឈ្មោះ សុវណ្ណា អាយុ២៦ឆ្នាំ។

កងរាជអាវុធហត្ថ បានមកដល់ផ្ទះផល្លានៅពេលយប់ម៉ោង ៨ល្ងាច ថ្ងៃអាទិត្យ នៅពេលដែលកុមារទាំងពីរកំពុងលេងនៅក្នុងផ្ទះ។ នៅពេលដែលកុមារទាំងពីរឃើញនគរបាល ភ្លាមនោះពួកគេចាប់ផ្ដើមយំនិងរត់ទៅក្រៅ។ នគរបាលដែលឃើញកុមារទាំងនោះ ភ្លាមៗបានឃាត់ខ្លួនស្ត្រីទាំងពីរ និងបាននាំខ្លួនអ្នកទាំងពីរ ទៅទីស្នាក់ការកងរាជអាវុធហត្ថមូលដ្ឋាន។

ផល្លាបានប្រាប់ អង្គការ លីកាដូ ថាគាត់បានសុំអង្វរនគរបាលថា "សូមមេត្តាអោយខ្ញុំទៅរកកូនប្រុសខ្ញុំ និងចៅប្រុសខ្ញុំមុនពេលលោកនាំខ្លួនខ្ញុំទៅ ពេលខ្ញុំរកឃើញហើយ ខ្ញុំនឹងទៅតាមលោក។" ប៉ុន្តែ កងរាជអាវុធហត្ថទាំងនោះ បានបដិសេធសំណូមពររបស់ផល្លា។

ទាល់តែដល់ម៉ោង ១០យប់ ថ្ងៃដដែល ទើបផល្លាអាចធ្វើការទាក់ទងតាមទូរស័ព្ទ ទៅប្រាប់ក្រុមគ្រួសារអំពីការឃាត់ខ្លួនរបស់គាត់ និងសួរអំពីសុវត្ថិភាពរបស់កូនប្រុស និងចៅប្រុសរបស់គាត់។ កូនស្រីមួយទៀត របស់ផល្លាបានប្រាប់ផល្លាថា អ្នកជិតខាងបានរកឃើញកុមារទាំងពីរកំពុងពួននៅក្នុងរណ្ដៅនៅដីស្រែមួយខាងក្រោយផ្ទះ។

ក្នុងអំឡុងពេល ការឃាត់ខ្លួន និងការឃុំខ្លួនរបស់អ្នកទាំងពីរ គ្មានពេលវេលាណាមួយ ដែលនគរបាលបានសាកសួរផល្លា ឬសុវណ្ណាថា តើអ្នកទាំងពីរមានកូនប៉ុន្មាននាក់ តើកុមារទាំងនោះនៅឯណា ឬ តើអ្នកណាអាចនឹងមើលថែកុមារទាំងពីរនោះ។ សុវណ្ណាត្រូវបានដោះលែងបន្ទាប់ពីស្នាក់នៅទីស្នាក់ការកងរាជអាវុធហត្ថមួយយប់ ប៉ុន្តែផល្លាត្រូវបានជំនុំជម្រះ និងផ្ដន្ទាទោស ពីបទល្មើសជួញដូរគ្រឿងញៀន និងត្រូវបានដាក់ទោស អោយជាប់ពន្ធនាគារចំនួនបីឆ្នាំ។ នៅក្នុងសវនាការ មិនមានការលើកឡើងណាមួយ អំពីកូនរបស់ផល្លានោះទេ។



"ខ្ញុំនៅផ្ទះម្នាក់ឯងជាមួយកូនតូចៗពីរនាក់។ ខ្ញុំសួរនគរបាលថាខ្ញុំគួរតែនាំទារករបស់ខ្ញុំមកជាមួយឬអត់ ប៉ុន្តែនគរបាលទាំងនោះឆ្លើយថាទេ។ បន្ទាប់មកខ្ញុំសួរថាខ្ញុំអាចចាំប្ដីរបស់ខ្ញុំមកផ្ទះសិនបានទេ ប៉ុន្តែនគរបាលឆ្លើយថាទេ អ្នកត្រូវមកតាមពួកខ្ញុំឥឡូវនេះ។ ដូច្នេះខ្ញុំទុកកូនង៉ែតរបស់ខ្ញុំនៅជាមួយអ្នកជិតខាង និងកូនប្រុសប្រាំពីរឆ្នាំនៅផ្ទះម្នាក់ឯង។ ខ្ញុំមិនអាចទូរស័ព្ទទៅប្ដីខ្ញុំរហូតដល់ថ្ងៃបន្ទាប់។"

កូនរបស់អ្នកជាប់ឃុំក្នុងពន្ធនាគារ ខែមីនា ឆ្នាំ២០១៥



កូនអ្នកជាប់ឃុំក្នុងពន្ធនាគារ ខែកុម្ភៈ ឆ្នាំ២០១៥

# ផលប៉ះពាល់លើកុមារ

មិនគួរអោយសង្ស័យនោះទេ ដែលនៅក្នុងករណីភាគច្រើន ការដាក់ពន្ធនាគារម្តាយអាចមានផលប៉ះពាល់យ៉ាងជ្រៅ និងរយៈពេលវែងលើចិត្តសាស្ត្រ និងការលូតលាស់របស់កូន ហើយអាចបង្កើនឱកាសដែលកុមារអាចនឹងប្រឆាំងនឹងច្បាប់នៅពេលក្រោយ។ នៅក្នុងផ្នែកខាងក្រោម អង្គការ លីកាដូ បានលំអិតអំពីរបៀបខុសៗគ្នាដែលកូនរបស់ក្រុមគ្រួសារដែលត្រូវបានសម្ភាស អាចទទួលរងផលប៉ះពាល់ ដូចដែលបានកត់សម្គាល់ដោយក្រុមគ្រួសារ និងកុមារខ្លួនឯងផ្ទាល់។

## ទំនាក់ទំនងម្តាយនិងកូន

នៅពេលដែលម្តាយត្រូវបានបញ្ជូនទៅពន្ធនាគារ និងត្រូវបានបំបែកចេញពីកូនមួយឬច្រើនរបស់នាង ផលប៉ះពាល់មួយនៃផលវិបាកជាក់ស្តែងបំផុតគឺ ផលប៉ះពាល់លើទំនាក់ទំនងម្តាយនិងកូន។

ស្ត្រីទាំងអស់ដែលត្រូវបានសម្ភាសដោយអង្គការ លីកាដូ គឺបានរស់នៅជាមួយ ឬមានការទំនាក់ទំនងជាទៀងទាត់ជាមួយនឹងកូនរបស់អ្នកទាំងនោះមុនពេលការឃាត់ខ្លួន។ ប៉ុន្តែនៅពេលដែលស្ត្រីទាំងនោះត្រូវបានឃាត់ខ្លួន ស្ត្រីមួយចំនួនមិនអាចទាក់ទងទៅកូនបានទាល់តែសោះ។ ស្ត្រី ៣២នាក់មិនបានទទួលការសួរសុខទុក្ខនៅក្នុងពន្ធនាគារណាមួយពីកូនឡើយ ហើយស្ត្រីច្រើននាក់ទៀតមិនអាចនិយាយជាមួយកូនរបស់អ្នកទាំងនោះតាមទូរស័ព្ទបានទេ។ មានតែស្ត្រីមួយចំនួនតូចប៉ុណ្ណោះ បានរាយការណ៍ថា កូនរបស់ខ្លួនអាចមកសួរសុខទុក្ខជាទៀងទាត់បាន ដោយស្ត្រីជាច្រើននាក់ទៀតទទួលបានការសួរសុខទុក្ខមួយដង ឬពីរដងប៉ុណ្ណោះពីកូន ក្នុងអំឡុងពេលឃុំឃាំង។

ក្រុមគ្រួសារបានផ្តល់មូលហេតុខុសៗគ្នាអំពីការខ្វះខាត ឬការកម្រអោយកូនចូលសួរសុខទុក្ខនៅក្នុងពន្ធនាគារ។ មូលហេតុសាមញ្ញបំផុតដែលទទួលបានគឺថា ក្រុមគ្រួសារមិនអាចលៃលកប្រាក់កាសទៅសួរសុខទុក្ខបាន ឬអាចត្រឹមតែលៃលកប្រាក់ទៅសួរសុខទុក្ខបានម្តងម្កាលប៉ុណ្ណោះ។ សំរាប់អ្នកឯទៀត គឺពន្ធនាគារនៅឆ្ងាយពេក ហើយជាពិសេសប្រសិនបើកុមារបានផ្លាស់ទីលំនៅទៅខេត្តមួយទៀត ឬមនុស្សពេញវ័យមិនអាចឈប់សំរាកពីការងារ ដើម្បីកំដរកុមារទៅសួរសុខទុក្ខបាន។

នៅពេលអ្នកថែទាំចំបងគឺជាសាច់ញាតិចាស់ទុំ ការធ្វើដំណើរទៅពន្ធនាគារមានពេលខ្លះមិនងាយស្រួល និងមិនអាចធ្វើបាន។ ការសិក្សារបស់កុមារក៏ជាមូលហេតុមួយនៃកង្វះខាតការសួរសុខទុក្ខផងដែរ ហើយនៅក្នុងករណីមួយចំនួន កុមារបានទៅធ្វើការងារដើម្បីទ្រទ្រង់ក្រុមគ្រួសារ និងមិនអាចឈប់សំរាកពីការងារបាន។ អង្គការ លីកាដូ កត់ត្រាបានតែករណីពីរទៅបីប៉ុណ្ណោះដែលកុមារមិនបានទៅសួរសុខទុក្ខដោយសារកុមារទាំងនោះមិនចង់ទៅ។

សំរាប់ម្តាយ និងកូនទាំងនោះដែលបានជួបគ្នា លក្ខខណ្ឌនៃការសួរសុខទុក្ខគឺមានការលំបាក ជាពិសេសការសួរសុខទុក្ខ ត្រូវបាន

ផ្ញើទ្បើងនៅខាងមុខរបារដែក ឬនៅខាងមុខផ្ទាំងកញ្ចក់ ហើយការជួបគ្នាតែងតែមានរយៈពេលខ្លី និងខ្វះភាពឯកជន។ មិនមានម្តាយណាមួយដែលត្រូវបានសម្ភាស ទទួលបានពេលវេលាមួយទល់និងមួយ ឬពេលវេលាឯកជនជាមួយនិងកូនរបស់អ្នកទាំងនោះ ក្នុងអំឡុងពេលសួរសុខទុក្ខរបស់ក្រុមគ្រួសារនោះទេ ហើយស្ត្រីជាច្រើននាក់មិនត្រូវបានអនុញ្ញាតអោយប៉ះពាល់រាងកាយកូនទាល់តែសោះ។

ដែលគួរអោយសោកស្តាយ ម្តាយមួយចំនួនបានប្រាប់អង្គការ លីកាដូ ថា កូនរបស់អ្នកទាំងនោះមិនស្គាល់ពួកគេទេនៅពេលមកសួរសុខទុក្ខ ជាពិសេសគឺកូនៗដែលអាចមកសួរសុខទុក្ខម្តងម្កាលប៉ុណ្ណោះ។ ម្តាយផ្សេងៗទៀតបានរាយការណ៍ថា កូនរបស់ពួកគេគឺនៅក្នុងសភាពទុក្ខព្រួយនៅពេលពួកគេជួបគ្នា។ មិនមានស្ត្រីណាម្នាក់ទទួលបានជម្រើសស្លៀកសំលៀកបំពាក់របស់ខ្លួនឯងផ្ទាល់ នៅពេលជួបជាមួយកូន ហើយជាធម្មតាមានវត្តមានអ្នកយាមក្នុងឯកសណ្ឋាននៅពេលសួរសុខទុក្ខ ធ្វើអោយមានភាពតានតឹងបន្ថែមទៀតទៅលើបរិយាកាស មិនរួសរាយរាក់ទាក់ មិនសូវស្និទ្ធស្នាល និងមិនស្រួលក្នុងចិត្ត។

ខណៈពេលដែលក្រុមគ្រួសារភាគច្រើនបានកត់សម្គាល់ថា កូនៗមានការសប្បាយចិត្តពេលជួបម្តាយ ក្រុមគ្រួសារជាច្រើនបានរាយការណ៍ថាកុមារទាំងនោះមានការមិនសប្បាយចិត្តមុនពេល អំឡុងពេល និងក្រោយពេលការសួរសុខទុក្ខ និងលក្ខខណ្ឌនៃការសួរសុខទុក្ខមានភាពតឹងរឹងដែលមិនចាំបាច់ត្រូវមាន។

**"ខ្ញុំសប្បាយចិត្តនៅពេលដែលអ្នកទាំងនោះមកសួរសុខទុក្ខខ្ញុំ ប៉ុន្តែកូនរបស់ខ្ញុំហាក់ដូចជាភ្លេចខ្ញុំ។ គេមិនចាំខ្ញុំទេ។"**

## ចំណងគ្រួសារផ្សេងទៀត

រចនាសម្ព័ន្ធក្រុមគ្រួសារ និងទំនាក់ទំនងរវាងបុគ្គលដទៃទៀតនៅក្នុងក្រុមគ្រួសារ ក៏អាចទទួលរងហានិភ័យផងដែរ នៅពេលដែលសមាជិកមួយឬច្រើន ត្រូវបានបញ្ជូនទៅពន្ធនាគារ។ ហើយដោយសារកុមារម្នាក់ទំនងជាអាចនឹងផ្លាស់ទីលំនៅ នៅពេលដែលម្តាយត្រូវបានឃាត់ខ្លួន ដូច្នេះផលប៉ះពាល់ទូលំទូលាយជាងនេះមកលើក្រុមគ្រួសារអាចមានសភាពធ្ងន់ធ្ងរឡើង។

នៅក្នុង ៣៨គ្រួសារនៃក្រុមគ្រួសារដែលបានស្ទង់មតិ កុមារម្នាក់ឬច្រើន បានផ្លាស់ទីលំនៅចេញពីផ្ទះគ្រួសាររបស់អ្នកទាំងនោះ ដែលជាលទ្ធផលនៃការជាប់ពន្ធនាគាររបស់ម្តាយ។ កុមារមួយចំនួនបានផ្លាស់ទីលំនៅទៅខេត្តមួយទៀត ហើយកុមារពីរទៅបីនាក់បានផ្លាស់ទីលំនៅទៅប្រទេសជិតខាង។ យ៉ាងតិចបំផុតនៅក្នុង ១១គ្រួសារ បងប្អូនត្រូវបានបំបែកចេញពីគ្នា ដោយសារតែកូនម្នាក់រស់នៅជាមួយម្តាយនៅក្នុងពន្ធនាគារ ឬដោយសារអ្នកទាំងនោះមានអ្នកមើលថែទាំចំបងខុសគ្នា។

នៅក្នុងករណីភាគច្រើន កុមារត្រូវបានថែទាំដោយសមាជិកក្រុមគ្រួសារមួយឬច្រើន បន្ទាប់ពីម្តាយអ្នកទាំងនោះត្រូវបានឃាត់ខ្លួន ដោយកុមារមួយចំនួនតូចរស់នៅជាមួយមិត្តភក្តិរបស់ក្រុមគ្រួសារ អ្នកជិតខាង ម្ចាស់ផ្ទះជួល ឬនៅមជ្ឈមណ្ឌលអង្គការមិនមែនរដ្ឋាភិបាលមួយ។ កុមារនៅក្នុងបួនគ្រួសារ មិនមានមនុស្សពេញវ័យមើលថែនោះទេ។

អង្គការ លីកាដូ បានកត់ត្រាបានត្រឹមតែ ១៨គ្រួសារប៉ុណ្ណោះ ដែលឪពុកដើរតួសំខាន់ក្នុងការថែទាំកូន និងអប់រំកូន។ នេះដោយសារតែឪពុកមានការមមាញឹកនឹងការងារ ដោយបានចេញពីផ្ទះទៅរកការងារនៅកន្លែងផ្សេងទៀត ឬដោយឪពុកនិងម្តាយបានបែកពីគ្នាមុនពេលឬចាប់ពីការឃាត់ខ្លួនមក។ អង្គការ លីកាដូ បានកត់ត្រាករណីជាច្រើនដែលឪពុកលែងមានទំនាក់ទំនងជាមួយនឹងកូន ឬមិនបានផ្តល់ជំនួយណាមួយដល់កូន ចាប់តាំងពីគេឃាត់ខ្លួនម្តាយ។

## ករណីសិក្សា៖ សុភាព

សុភាព មានកូនប្រុសបីនាក់ អាយុ ៩ឆ្នាំ ៧ឆ្នាំ និង២ឆ្នាំ។ មុនពេលនាងត្រូវបានឃាត់ខ្លួន នាងរស់នៅជាមួយស្វាមី និងកូនបីនាក់ និងធ្វើការជាមេផ្ទះ។ ស្វាមីរបស់នាងរកប្រាក់ផ្គត់ផ្គង់គ្រួសារ ដោយមុខរបរជាអ្នករត់ម៉ូតូឌុប។

នៅពេលដែល នាងត្រូវបានឃាត់ខ្លួនពីបទល្មើសចោរកម្ម នៅខែ មករា ឆ្នាំ ២០១៤ កូនប្រុសពៅរបស់សុភាពគឺមានអាយុត្រឹមតែ ៩ខែ ប៉ុណ្ណោះ។ នាងត្រូវបាននាំខ្លួនចេញពីផ្ទះ ហើយដោយមិនដឹងថា នាងនឹងត្រូវគេបញ្ជូនទៅពន្ធនាគារនោះទេ នាងក៏យកកូនពៅទៅប៉ុស្តិ៍នគរបាលមូលដ្ឋានជាមួយគ្នា។ កូនពៅរបស់នាងនៅជាមួយនាងនៅក្នុងពន្ធនាគារ រហូតដល់ថ្ងៃដោះលែង នៅខែមេសា ឆ្នាំ២០១៥។

នៅពេលការឃាត់ខ្លួន ស្វាមីរបស់នាង និងកូនពីរនាក់ទៀត ក៏កំពុងនៅផ្ទះដែរ ប៉ុន្តែពួកគេមិនបានបង្ហាញវត្តមានអោយនគរបាលបានដឹង ហើយនគរបាល ក៏មិនបានសួររកពួកគេដែរ។

សុភាព ត្រូវបានកាត់ទោសក្នុងរយៈពេលតិចជាង ៦សប្តាហ៍ បន្ទាប់ពីការឃាត់ខ្លួន ហើយនាងត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារ រយៈពេល បួនឆ្នាំ។ ក្រុមគ្រួសាររបស់នាង បានជួលមេធាវីឯកជនដើម្បីការពារក្តីអោយនាង ប៉ុន្តែក្នុងអំឡុងពេលការឃាត់ខ្លួន និងការដាក់ទោស នគរបាល តុលាការ ឬ មេធាវីមិនបានសាកសួរសុភាពថា តើនាងមានកូនប៉ុន្មាននាក់ ឬថាតើមានអ្នកណាមើលថែកូនរបស់នាង ប្រសិនបើនាងត្រូវបញ្ជូនទៅពន្ធនាគារ។

សុភាពមិនបានដឹងថាក្រុមគ្រួសាររបស់នាងបង់ប្រាក់ប៉ុន្មាន សំរាប់សេវាកម្មរបស់មេធាវីនោះទេ ប៉ុន្តែមិនយូរប៉ុន្មានបន្ទាប់ពីសវនាការជំនុំជម្រះ ទាំងឪពុកម្តាយ និងស្វាមីរបស់នាង បានសម្រេចចិត្តធ្វើដំណើរឆ្លងព្រំដែនទៅប្រទេសថៃ ដើម្បីស្វែងរកការងារសំណង់ធ្វើសម្រាប់ទប់ទល់ និងការចំណាយទាក់ទងនឹងការជាប់ពន្ធនាគាររបស់នាង។ កូនប្រុសច្បងរបស់នាង ត្រូវបានបញ្ជូនទៅរស់នៅជាមួយមីង នៅខេត្តមួយទៀត ដែលគេអាចបន្តការសិក្សាបាន ចំណែកឯកូនកណ្តាល បានធ្វើដំណើរទៅជាមួយយាយ និងតាទៅប្រទេសថៃ ហើយកូននោះទៅជាមួយយាយ និងតារបស់គេទៅការដ្ឋានសំណង់ជារៀងរាល់ថ្ងៃ។

## ការអប់រំ

ម្ដាយជាច្រើននាក់ដែលត្រូវបានសម្ភាសដោយអង្គការ លីកាដូ បានបង្ហាញនូវការព្រួយបារម្ភអំពីផលប៉ះពាល់នៃការជាប់ពន្ធនាគាររបស់អ្នកទាំងនោះទៅលើការសិក្សារបស់កូន។ ស្ត្រីមួយចំនួនមិនដឹងថាកូនរបស់ខ្លួន នៅតែបន្តទៅសាលារៀនដែរឬទេ ចំណែកឯស្ត្រីផ្សេងទៀតបានឮថាកូនរបស់ខ្លួនមិនអាចបន្តតាំងអារម្មណ៍សិក្សានៅសាលារៀនបានទៀតទេ ហើយជាលទ្ធផលពិន្ទុរបស់កូនៗទាំងនោះបានធ្លាក់ចុះ។

ដូចដែលអង្គការ លីកាដូ បានរកឃើញ បញ្ហាទាំងនេះគឺមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។ លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញអោយឃើញថា នៅពេលដែលម្ដាយម្នាក់ត្រូវបានជាប់ពន្ធនាគារ ជាលទ្ធផលការសិក្សារបស់កូនតែងតែទទួលរងការប៉ះពាល់។ កុមារមួយចំនួនបានឈប់សិក្សា ចំណែកឯកុមារផ្សេងទៀតចាប់ផ្ដើមធ្វើការងារក្រៅម៉ោងសិក្សា ដើម្បីជួយផ្គត់ផ្គង់គ្រួសារ។ កុមារដែលផ្លាស់ទីលំនៅចេញពីផ្ទះគ្រួសាររបស់អ្នកទាំងនោះ តែងតែត្រូវការប្ដូរសាលារៀន ហើយចំពោះកុមារដែលបន្តសិក្សានៅសាលារៀនដដែលត្រូវបានរាយការណ៍ថាពួកគេមានការពិបាកក្នុងការសិក្សា។ គ្រួសារជាច្រើនបានកត់សម្គាល់ថា ដោយសារម្ដាយត្រូវបានឃាត់ខ្លួន មិនមានអ្នកណាម្នាក់អាចជួយកិច្ចការសាលារបស់កុមារ ឬរៀបចំអោយកុមារទៅសាលារៀនបានទេ។

## "ចាប់តាំងពីការឃាត់ខ្លួនខ្ញុំមក កូនខ្ញុំគេចមិនចូលសាលា ហើយទៅភោជនីយដ្ឋានប្រមូលកំប៉ុង។ឥឡូវកូននេះត្រូវតែធ្វើការងារនេះពីព្រោះកូនខ្ញុំអត់មានអាហារទទួលទានគ្រប់គ្រាន់ទេ។"

## ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ

នៅពេលដែលសមាជិកគ្រួសារម្នាក់ត្រូវបានឃាត់ខ្លួន និងបញ្ជូនទៅពន្ធនាគារ ផលប៉ះពាល់ហិរញ្ញវត្ថុទៅលើក្រុមគ្រួសារ គឺតែងតែកើតមានឡើងភ្លាមៗ និងមានរយៈពេលវែង។ ដោយសារតែអំពើពុករលួយដែលមាននៅក្នុងគោលនយោបាយ និងរចនាសម្ព័ន្ធតុលាការនៅកម្ពុជា[៩] ជនសង្ស័យដែលមានប្រាក់តែងតែអាចបង់ប្រាក់សំរាប់នៅក្រៅតុលាការ និងពន្ធនាគារ។ ជាលទ្ធផល អ្នកដែលត្រូវបានបញ្ជូនទៅអោយឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ និងនៅទីបំផុតត្រូវជាប់ទោស គឺតែងតែជាអ្នកមកពីក្រុមគ្រួសារក្រីក្រដែលងាយរងផលប៉ះពាល់បំផុតពីការធ្លាក់ចុះនៃចំណូល។

ក្រុមគ្រួសារមួយចំនួនបានរាយការណ៍ថានៅពេលឃាត់ខ្លួន នគរបាលបានយកប្រាក់ពីក្រុមគ្រួសារ និងបានរឹបអូសយកទ្រព្យសម្បត្តិដែលមិនពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតទុកជាអចិន្ត្រៃយ៍។ ប្រសិនបើម្ដាយជាអ្នករកប្រាក់ ភ្លាមៗនោះគ្រួសារនឹងបាត់បង់ប្រភពចំណូលទៀងទាត់មួយ ហើយនៅក្នុងករណីមួយចំនួនទៀត សមាជិកគ្រួសារផ្សេងទៀតបានលះបង់ការងាររបស់អ្នកទាំងនោះដើម្បីមើលថែទាំកុមារ និងធ្វើការងារផ្ទះ។

នៅក្នុងករណីមួយចំនួនតូចផ្សេងទៀត ដែលស្ត្រី ឬក្រុមគ្រួសាររបស់ស្ត្រីបានបង់ប្រាក់អោយអ្នកតំណាងផ្លូវច្បាប់ជាឯកជន ប្រាក់ឈ្នួលហួសហេតុរបស់មេធាវីបាននាំអោយគ្រួសារកាន់តែក្រីក្រឡើង ហើយជាញឹកញាប់មេធាវីទាំងនេះផ្ដល់សេវាមកវិញតិចតួចណាស់។ គ្រួសារមួយចំនួនបានរាយការណ៍ថាអ្នកទាំងនោះចាំបាច់ត្រូវតែលក់ដី និងទ្រព្យសម្បត្តិផ្សេងៗទៀតរបស់ពួកគេ ដើម្បីបង់ប្រាក់ឈ្នួលផ្លូវច្បាប់ និងការចំណាយផ្សេងៗទៀតទាក់ទងនិងពន្ធនាគារ។

### ករណីសិក្សា៖ សុភាព (ត)

នៅពេលអង្គការលីកាដូ ជួបជាមួយសុភាព នាងនិងប្ដីរបស់នាងមិនអាចធ្វើការទាក់ទងផ្ទាល់ជាមួយកូនៗ នៅប្រទេសថៃ និងខេត្តបាត់ដំបងបានទេ។ ស្វាមីរបស់នាងធ្វើដំណើរទៅមកប្រទេសថៃដើម្បីធ្វើការងារ និងដើម្បីផ្ញើប្រាក់មួយចំនួនមកជួយផ្គត់ផ្គង់កូន ប៉ុន្តែគាត់ មិនអាចទៅជួបកូនរបស់គាត់បានទេ។ សុភាពបានត្រឹមតែ និយាយជាមួយកូនៗ របស់នាងម្ដងម្កាលនៅក្នុងពន្ធនាគារ ដោយប្រើប្រាស់ទូរស័ព្ទដៃឆ្នាំគុកប៉ុណ្ណោះ។

ដោយស្ដាប់តាមការណែនាំ ពីមេធាវីរបស់នាង សុភាពប្ដឹងតវ៉ានឹងការដាក់ទោសរបស់នាង ប៉ុន្តែបន្ទាប់ពីរង់ចាំរយៈពេលយូរ ដោយគ្មានការបើកសវនាការឡើងវិញ នាងសម្រេចចិត្តដកពាក្យបណ្ដឹងតវ៉ា។ នាងនឹងត្រូវដោះលែងនៅខែមករា ឆ្នាំ២០១៦ ប៉ុន្តែនាងទទួលបានព្រះរាជទានលើកលែងទោស និងត្រូវបានដោះលែងជាមួយនិងស្ត្រី ៣៦នាក់ផ្សេងទៀតមុនបុណ្យចូលឆ្នាំខ្មែរ នៅខែមេសា ឆ្នាំ២០១៥។

---

៩ សំរាប់ព័ត៌មានបន្ថែមអំពីអំពើពុករលួយក្នុងពន្ធនាគារកម្ពុជាសូមមើលរបាយការណ៍របស់អង្គការលីកាដូ "សិទ្ធិនៅលើការ ទិញដូរ៖ ជីវិតនៅក្នុងពន្ធនាគារកម្ពុជា" http://www.licadho-cambodia.org/collection/25/life_inside_cambodia_prison

ការចំណាយទៅសួរសុខទុក្ខនៅពន្ធនាគារ ក៏ជាបញ្ហាហិរញ្ញវត្ថុដ៏សំខាន់មួយសំរាប់គ្រួសារជាច្រើនផងដែរ ជាពិសេសសំរាប់គ្រួសារដែលរស់នៅទីជនបទដាច់ស្រយាល។ បន្ថែមពីលើការចំណាយធម្មតានៃការធ្វើដំណើរទៅពន្ធនាគារ ការឈប់សំរាកពីការងារនិងការរៀបចំមើលថែទាំកុមារ នៅពន្ធនាគារកម្ពុជាភាគច្រើនអ្នកសួរសុខទុក្ខតម្រូវអោយបង់ប្រាក់ទៅអោយពន្ធនាគារ សំរាប់ការសួរសុខទុក្ខម្តងៗ។

ដោយសារកង្វះខាតអាហារបំប៉ន ថ្នាំពេទ្យមានប្រសិទ្ធិភាព និងគ្រឿងផ្គត់ផ្គង់សាមញ្ញផ្សេងៗទៀតនៅក្នុងពន្ធនាគារ ដូច្នេះអ្នកសួរសុខទុក្ខជាធម្មតាតែងតែនាំយកប្រាក់ ចំណីអាហារ ឬសម្ភារៈផ្សេងៗទៅអោយអ្នកជាប់ពន្ធនាគារ។ ដើម្បីធ្វើបែបនេះ អ្នកទាំងនោះជាញឹកញាប់តម្រូវអោយបង់ប្រាក់បន្ថែមទៀត ឬកាត់ភាគរយនៃរបស់របរទាំងនោះទៅអោយឆ្មាំពន្ធនាគារផងដែរ។

**"យើងបង់លុយឲ្យមេធាវី ១.០០០ដុល្លារ ប៉ុន្តែខ្ញុំបានជួបគាត់តែម្តងគត់ នៅថ្ងៃបន្ទាប់ពីការឃាត់ខ្លួនរបស់ខ្ញុំ។ មេធាវីនោះមិនដែលទៅជួបខ្ញុំនៅក្នុងពន្ធនាគារទេ ហើយទោះបីជាគាត់មានវត្តមាននៅសវនាការជំនុំជម្រះក៏ដោយ ក៏គាត់មិនបាននិយាយអ្វីទាំងអស់។ គាត់មិនដែលសួរខ្ញុំ ថាតើខ្ញុំមានកូនប៉ុន្មាននាក់ទាល់តែសោះ។"**

## សុខភាព

អង្គការ លីកាដូ បានចងក្រងជាឯកសាររួចរាល់ហើយអំពីផលប៉ះពាល់អវិជ្ជមាន នៃជីវិតក្នុងពន្ធនាគារទៅលើសុខភាពនៃស្ត្រីមានផ្ទៃពោះ ម្តាយនិងកុមារនៅក្នុងពន្ធនាគារដោយសារតែការខ្វះខាតថ្នាំពេទ្យ និងអាហារបំប៉ននៅក្នុងពន្ធនាគារ ប៉ុន្តែមានការយកចិត្តទុកដាក់តិចតួចណាស់ចំពោះផលប៉ះពាល់ទៅលើកុមារដែលរស់នៅខាងក្រៅពន្ធនាគារ និងដែលពីមុនមកកុមារទាំងនោះពឹងផ្អែកលើម្តាយសំរាប់អាហារបំប៉ន ការថែទាំសុខភាព និងការគាំទ្រផ្លូវចិត្ត។

ស្ត្រីនិងគ្រួសារជាច្រើនដែលត្រូវបានសម្ភាសដោយអង្គការលីកាដូមានការព្រួយបារម្ភថា សុខភាពកុមារបានទទួលរងផលប៉ះពាល់ ដោយសារលទ្ធផលនៃការជាប់ពន្ធនាគាររបស់ម្តាយ ហើយជាពិសេសគឺទារកដែលកំពុងនៅត្រូវការការបំបៅដោះ នៅពេលដែលម្តាយត្រូវបានឃាត់ខ្លួន។

នៅពេលដែលទារកត្រូវបានបំបែកចេញពីម្តាយ អ្នកមើលថែមួយចំនួនបានប្រាប់អង្គការលីកាដូថា ពួកគេ មិនអាចលៃលកទិញម្សៅទឹកដោះគោអោយទារកបានទេ។ សំរាប់ កុមារអាយុច្រើនជាងនេះ ក្រុមគ្រួសារជាច្រើនបានរាយការណ៍ថា ពួកគេមិនមានប្រាក់គ្រប់គ្រាន់ដើម្បីទិញចំណីអាហារគ្រប់គ្រាន់អោយកុមារទាំងនោះទេ ហើយនៅពេលដែលកុមារទាំងនោះមានជំងឺ អ្នកទាំងនោះមិនមានលទ្ធភាពយកកុមារទៅរកគ្រូពេទ្យ ឬទិញថ្នាំបានទេ។

នៅពេលអ្នកមើលថែកុមារ គឺជាសាច់ញាតិចាស់ទុំ អ្នកទាំងនោះជាញឹកញាប់បានរាយការណ៍ថា តម្រូវការក្នុងការថែទាំកុមារ គឺមានផលប៉ះពាល់អវិជ្ជមានមកលើសុខភាពរបស់អ្នកទាំងនោះ និងសមត្ថភាពរបស់ពួកគេ ក្នុងការមើលថែកុមារប្រកបដោយសុវត្ថិភាព និងប្រសិទ្ធិភាព។

បន្ថែមពីលើផលប៉ះពាល់សុខភាពរាងកាយ ទៅលើកុមារ អង្គការលីកាដូ ក៏បានឮអំពីការរាយការណ៍ជាច្រើនដែលកុមារទទួលរងផលប៉ះពាល់ផ្នែកសតិអារម្មណ៍ដោយសារការជាប់ពន្ធនាគាររបស់ម្តាយពួកគេ។ ក្នុងចំណោមបញ្ហាផ្សេងៗទៀត គឺកុមារប្រឈមមុខ នឹងបញ្ហាការទទួលទានដំណេកមិនគ្រប់គ្រាន់ ការធ្លាក់ទឹកចិត្ត និងការមិនអាចផ្តោតអារម្មណ៍សិក្សាបាន។

## ការរស់នៅប្រចាំថ្ងៃ និងទំនាក់ទំនងសង្គម

ម្តាយ អ្នកថែទាំ និងកុមារខ្លួនឯងក៏បានកត់សម្គាល់ ផងដែរ អំពីបញ្ហានៃផលប៉ះពាល់លើការរស់នៅប្រចាំថ្ងៃរបស់កុមារ និងស្លាកស្នាមអាម៉ាស់ដែលកុមារត្រូវប្រឈមមុខនឹងមិត្តភក្តិ អ្នកជិតខាង និងគ្រូនៅសាលារៀន។

ដោយសារតែស្ត្រីជាធម្មតាដើរតួនាទីសំខាន់ នៅក្នុងក្រុមគ្រួសារមុនពេលការឃាត់ខ្លួន ដូច្នេះអវត្តមានរបស់ស្ត្រីតែងតែត្រូវបានចាប់អារម្មណ៍ នៅពេលគិតដល់កិច្ចការងារផ្ទះ ការរៀបចំអោយកូនទៅសាលារៀន និងការងារប្រចាំថ្ងៃផ្សេងៗទៀត។ ហេតុនេះកុមារខ្លួនឯងផ្ទាល់ជាញឹកញាប់ត្រូវតែធ្វើកិច្ចការងារទាំងនេះជំនួសអោយម្តាយ។

ការជាប់ពន្ធនាគាររបស់ម្តាយ ត្រូវបានលើកឡើងដោយគ្រួសារមួយចំនួនថាជាប្រភពនៃការបាត់បង់កិត្តិយស និងធ្វើអោយមានស្លាកស្នាមអាម៉ាសដល់កុមារ ក្នុងការប្រាស្រ័យទាក់ទងប្រចាំថ្ងៃនៅផ្ទះ ឬនៅសាលារៀន ដោយគ្រួសារមួយចំនួនបានរាយការណ៍ថាកុមារមិនចង់ចេញពីផ្ទះ ឬក៏និយាយជាមួយមិត្តភក្តិ ឬអ្នកជិតខាងឡើយ។ ម្តាយម្នាក់បានប្រាប់អង្គការលីកាដូថា កូនស្រីរបស់គាត់ត្រូវបានគេប្រាប់ថា នាងមិនអាចលេងជាមួយមិត្តភក្តិរបស់នាងបានទៀតទេ ពីព្រោះឪពុកម្តាយរបស់ពួកគេមិនចង់អោយពួកគេលេងជាមួយ "កូនចោរ"។ កុមារផ្សេងទៀតត្រូវបានកុមារដទៃធ្វើបាបនៅសាលារៀនដោយសារតែម្តាយអ្នកទាំងនោះជាប់ពន្ធនាគារ។

"កូនឈឺខ្លាំងណាស់ឥឡូវ ហើយយំខ្លាំងណាស់ពេលយប់។ យើងបានផុងទឹកដោះគោអោយកូននេះបៅ ប៉ុន្តែឥឡូវយើងអត់មានលទ្ធភាពទិញទៀតទេ។"

## ផលប៉ះពាល់ជាពិសេសចំពោះភេទ

ដោយគ្មានមន្ទិលសង្ស័យ កុមារជាច្រើនទទួលរងផលប៉ះពាល់អវិជ្ជមានជាច្រើន នៅពេលដែលសមាជិកគ្រួសារដែលជិតស្និទ្ធម្នាក់ត្រូវបានបញ្ជូនទៅពន្ធនាគារ ប៉ុន្តែការស្រាវជ្រាវរបស់អង្គការ

លីកាដូ បានបង្ហាញអោយឃើញថា ផលប៉ះពាល់ភាគច្រើនមានសភាពធ្ងន់ធ្ងរនៅពេលដែលអ្នកជាប់ពន្ធនាគារគឺជាម្តាយ។

ដោយសារតែឋានៈរបស់ស្ត្រីនៅក្នុងសង្គមកម្ពុជា និងដោយសារតែស្ត្រីជាទូទៅមិនមែនជាអ្នករកប្រាក់ចំណូល និងជាពិសេសប្រសិនបើស្ត្រីជាម្តាយ ដូច្នេះជាទូទៅស្ត្រីមិនទំនងជាអាចលៃលករកប្រាក់សំណូកដើម្បីដោះខ្លួនចេញពីការឃុំឃាំង ឬបង់ប្រាក់សំរាប់ការបន្ធូរបន្ថយទោសបានទេ។ ម្យ៉ាងទៀត ក្រុមគ្រួសារជាច្រើនហាក់បីដូចជាមិនចង់ធ្វើការចំណាយប្រាក់ ដើម្បីការដោះលែងរបស់ស្ត្រីទាំងនោះ ឬដើម្បីជួលមេធាវីម្នាក់ទេ ប៉ុន្តែក្រុមគ្រួសារប្រហែលជាអាចធ្វើការចំណាយប្រាក់ លើអ្នកដែលរកប្រាក់ចំណូលចំបង ដែលជាធម្មតាគឺជាបុរស ប្រសិនបើអ្នកទាំងនោះ ត្រូវបានឃាត់ខ្លួន។

ដោយសារស្ត្រីច្រើនតែងទទួលយកតួនាទីមើលថែកូន និងធ្វើកិច្ចការផ្ទះ ដូច្នេះការរស់នៅប្រចាំថ្ងៃរបស់គ្រួសារទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ នៅពេលដែលស្ត្រីជាប់ពន្ធនាគារ ហើយពីមុនមកឪពុកជាញឹកញាប់មានការចូលរួមតិចតួច នៅក្នុងការរៀបចំអោយកូនទៅសាលារៀន ការងារប្រចាំថ្ងៃ និងតម្រូវការសម្ភារៈសាមញ្ញៗ។ ដោយសារកុមារតែងតែចំណាយពេលវេលានៅជាមួយម្តាយ និងបង្កើតចំណងជិតស្និទ្ធ ដូច្នេះឥទ្ធិពលរយៈពេលវែងនៃអវត្តមានរបស់ម្តាយ ក៏ទំនងជាអាចមានសភាពធ្ងន់ធ្ងរផងដែរ។

លទ្ធផលរកឃើញរបស់អង្គការលីកាដូ ក៏បានបង្ហាញផងដែរថាសុខភាពរបស់កុមារ រងការគម្រាមកំហែងខ្លាំងក្លា នៅពេលដែលម្តាយរបស់អ្នកទាំងនោះជាប់ពន្ធនាគារ ដោយមានហានិភ័យខ្ពស់ ដែលកុមារអាចនឹងចាកចេញពីផ្ទះគ្រួសាររបស់អ្នកទាំងនោះ ដើម្បីទៅរស់នៅជាមួយអ្នកណាផ្សេង ប្រហែលជានៅក្នុងភូមិមួយទៀត ឬខេត្តមួយទៀត ហើយនៅក្នុងករណីមួយចំនួន បងប្អូនត្រូវបានបំបែកចេញពីគ្នាទៀតផង។ ជាលទ្ធផល កុមារទាំងនោះក៏ទំនងជាត្រូវប្តូរសាលារៀន និងរស់នៅបែកពីឪពុកម្តាយទាំងពីរទៀតផងដែរ។

ការសួរសុខទុក្ខនៅពន្ធនាគាររបស់គ្រួសារជាច្រើនតែងតែមានការលំបាកក្នុងការរៀបចំ នៅពេលដែលម្តាយនៅក្នុងពន្ធនាគារ។ មិនត្រឹមតែដោយសារតែទីតាំងភូមិសាស្ត្ររបស់អ្នកទាំងនោះ ប៉ុន្តែដោយសារតែកុមារភាគច្រើន បានទៅរស់នៅជាមួយនឹងសាច់ញាតិចាស់ទុំដែលមិនមានមធ្យោបាយជាក់ស្តែង ឬហិរញ្ញវត្ថុ ដើម្បីរៀបចំការទៅសួរសុខទុក្ខម្តាយនៅពន្ធនាគារ។

សាច់ញាតិមួយចំនួន គឺមានរាងកាយទន់ខ្សោយ ឬមិនមានសមត្ថភាព ដើម្បីធ្វើដំណើរជាទៀងទាត់ទៅពន្ធនាគារដោយខ្លួនឯងនោះទេ ចុះទម្រាំធ្វើការពិចារណាលើការធ្វើដំណើរទៅជាមួយកុមារតូចៗទៀតនោះ។ ម្យ៉ាងទៀត ស្ត្រីគឺមិនសូវជាទទួលបានការងារធ្វើនៅក្នុងពន្ធនាគារដើម្បីរកប្រាក់កម្រៃដូចជាបុរសនោះទេ[១០] ដូច្នេះស្ត្រីមិនទំនងជាអាចជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ ទៅដល់ការសួរសុខទុក្ខរបស់គ្រួសារ ឬបង់ថ្លៃទូរស័ព្ទនោះទេ។

ការស្រាវជ្រាវរបស់ អង្គការ លីកាដូ បង្ហាញអោយឃើញថាជាទូទៅទាំងកុមារី និងកុមារា គឺទទួលរងផលប៉ះពាល់ស្មើគ្នាដោយការជាប់ពន្ធនាគាររបស់ម្តាយ ប៉ុន្តែផលប៉ះពាល់ជាក់ស្តែងច្រើនតែមានភាពប្រែប្រួល។ កុមារាភាគច្រើនតែងតែគេចមិនចូលសាលារៀន ឬតម្រូវអោយធ្វើការងារដើម្បីផ្គត់ផ្គង់គ្រួសារ ចំណែកកុមារីភាគច្រើនត្រូវតែធ្វើការងារផ្ទះ ឬទទួលខុសត្រូវមើលថែប្អូនតូចៗ។

"មុនដំបូងគេឃាត់ខ្លួនស្វាមីរបស់ខ្ញុំ ហើយនៅពេលដែលខ្ញុំទៅសួរសុខទុក្ខគាត់ គេចាប់ទាំងខ្ញុំទៀត។ បន្ទាប់ពីជាប់ឃុំឃាំងពីរយប់ ពួកយើងខ្ចីលុយពីធនាគារ ១.០០០ដុល្លារ ឲ្យទៅនគរបាលដើម្បីអោយដោះលែងស្វាមីខ្ញុំ។ គេសួររកលុយសំរាប់ដោះលែងខ្ញុំដែរ ប៉ុន្តែយើងអត់មានលុយទៀតទេ។"

[១០] ដូចជាការងារសំណង់ ការងារធ្វើគ្រឿងសង្ហារឹម ការងារផ្សារដែក និងការងារកសិកម្ម។

## ករណីសិក្សា៖ កញ្ញា

កញ្ញាមានកូនបួននាក់ ដែលមានអាយុ ១៥ឆ្នាំ (ប្រុស) ១៣ឆ្នាំ (ស្រី) ១០ឆ្នាំ (ស្រី) និង ៣ឆ្នាំ (ប្រុស)។ ទាំងនាង និងស្វាមីរបស់នាងត្រូវជាប់ពន្ធនាគារ ពីបទល្មើស ជួញដូរគ្រឿងញៀន។ យោងតាមកញ្ញា ស្វាមីរបស់នាងបានទិញគ្រឿងញៀនពីភ្នំពេញ ប៉ុន្តែនគរបាលបានតាមដានគាត់មកដល់ផ្ទះ និងបានឃាត់ខ្លួនទាំងនាងផងដែរ ដោយគ្រាន់តែនាងមានវត្តមាននៅពេលឃាត់ខ្លួន។

កូនទាំងអស់របស់កញ្ញានៅផ្ទះជាមួយនិងលោកយាយរបស់អ្នកទាំងនោះ នៅពេលដែលនគរបាលបានមកដល់។ ប៉ុន្តែនគរបាលមិនបានសួរថាតើអ្នកណាអាច មើលថែកុមារទាំងនោះបាន ផ្ទុយទៅវិញនគរបាលបានបង្គាប់អោយពួកគេនៅស្ងៀម និងមិនបាននិយាយ អ្វីទាំងអស់ គឺគ្រាន់តែដាក់ខ្នោះឪពុកម្តាយរបស់អ្នកទាំងនោះ និងនាំខ្លួនទៅប៉ុស្តិ៍នគរបាលមូលដ្ឋាន។ នៅពេលការឃាត់ខ្លួនរបស់កញ្ញា កូនពៅ របស់នាងទើបតែមានអាយុ ពីរឆ្នាំប៉ុណ្ណោះ ប៉ុន្តែនគរបាលមិនបានផ្តល់ជម្រើសអោយនាងក្នុងការនាំកូនទៅជាមួយ។ ក្រោយមក នៅពេលដែលនាងស្នើសុំយកកូនទៅជាមួយនាងនៅក្នុងពន្ធនាគារ នគរបាលបានប្រាប់នាងថាសំណូមពរនាងមិនអាចទទួលយកបានទេ។

ម្តាយអាយុ ៨១ឆ្នាំរបស់កញ្ញា ឥឡូវនេះគឺជាអ្នកមើលថែតែមួយគត់លើកុមារ ទាំងបួន។ គាត់មានជំងឺ ហើយនៅពេលដែលអង្គការលីកាដូទៅជួបគាត់ គាត់ទើបតែមានជំងឺរលាកជើងធ្ងន់ធ្ងរ បន្ទាប់ពីគាត់ដួលលើឆ្នាំងទឹកក្តៅ នៅពេលដែលគាត់ប្រញាប់ប្រញាល់រៀបចំអាហារថ្ងៃត្រង់អោយចៅ មុនពេលក្មេងៗត្រលប់មកពីសាលារៀនវិញ។ គាត់កំពុងតែនៅក្នុងសភាពឈឺចាប់ នៅពេលអង្គការលីកាដូទៅសួរសុខទុក្ខគាត់ ហើយគាត់មានការពិបាកក្នុងការសម្រានពេលយប់ និងមិនមានលទ្ធភាពទៅរកគ្រូពេទ្យបានទេ។

ចាប់តាំងពីឧបទ្ទវហេតុនេះមក កូនស្រីអាយុ ១៣ឆ្នាំរបស់កញ្ញា ភាគច្រើនគឺជា អ្នកធ្វើម្ហូប កិច្ចការងារផ្ទះ និងបោកគក់សំលៀកបំពាក់ នៅពេលដែលនាងត្រលប់មកពីសាលារៀនវិញ។ នាងក៏ទទួលយកការទទួលខុសត្រូវមើលថែទាំប្អូនតូចៗរបស់នាងផងដែរ។ កូនប្រុសច្បងរបស់កញ្ញាបានឈប់រៀន និងចាប់ផ្តើមធ្វើការងារនៅចំការមួយនៅជិតផ្ទះ។

មុនពេលការឃាត់ខ្លួនកញ្ញា នាងបើកហាងលក់គ្រឿងទេសតូចមួយនៅផ្ទះ ប៉ុន្តែបន្ទាប់ពីគ្រួសាររបស់នាងបានលក់ទំនិញដែលនៅសេសសល់ទាំងអស់ ពួកគេមិនមានលទ្ធភាពទិញទំនិញយកមកទុកលក់បានទៀតទេ ដោយសារការចំណាយទាក់ទងនឹងការជាប់ពន្ធនាគារ។ ឥឡូវនេះហាងរបស់អ្នកទាំងនោះត្រូវបានបិទហើយ។ ដោយគ្មានប្រភពចំណូលទៀងទាត់ លើកលែងតែប្រាក់កម្រៃរបស់កូនប្រុសអាយុ ១៥ឆ្នាំ ដូច្នេះគ្រួសារត្រូវបង្ខំចិត្តលក់ដីធ្លីមួយចំនួនដើម្បីដោះស្រាយការចំណាយរស់នៅប្រចាំថ្ងៃ។

ម្តាយរបស់កញ្ញាបានត្រឹមតែទៅសួរសុខទុក្ខកូនស្រីតែ ២ដងប៉ុណ្ណោះ នៅក្នុងពន្ធនាគារ ដោយគាត់បានយកតែកូនប្រុសអាយុ ៣ឆ្នាំ ទៅតាមជាមួយរាល់លើក។ គ្រួសាររបស់នាងមិនមានលទ្ធភាពទៅសួរសុខទុក្ខអោយបានទៀងទាត់ទេ ដោយសារការធ្វើដំណើរតាមតាក់ស៊ីទៅពន្ធនាគារត្រូវការចំណាយពេលមួយម៉ោងកន្លះ និងត្រូវចំណាយ ៧ដុល្លារ ដើម្បីធ្វើដំណើរត្រលប់ទៅវិញ។ នៅពេលទៅដល់ពន្ធនាគារ ពួកគាត់ត្រូវបង់ប្រាក់ ៣ដុល្លារ សំរាប់ការសួរសុខទុក្ខ ១៥ នាទីនៅខាងមុខរបារដែក ហើយប្រសិនបើពួកគាត់ចង់ជួបឪពុកម្តាយទាំងពីរនាក់ ពួកគាត់ត្រូវបង់ប្រាក់ទ្វេដង។ ក្រុមគ្រួសារមិនមានលទ្ធភាពបង់ប្រាក់ ៥ដុល្លារ សំរាប់ការសួរសុខទុក្ខ ដែលពួកគាត់អាចប៉ះពាល់រាងកាយគ្នាបាន។

កញ្ញាបានប្រាប់អង្គការលីកាដូថា នៅពេលដែលកូនប្រុសពៅរបស់នាងមកសួរសុខទុក្ខ គេបានយំនៅពេលដែលគេឃើញនាង និងគេហាក់បីដូចជាមិនស្គាល់នាង ដែលស្លៀកពាក់ឯកសណ្ឋានពន្ធនាគារ។ នាងមិនអាចនិយាយជាមួយគ្រួសាររបស់នាងតាមទូរស័ព្ទបានទៀងទាត់ទេ ពីព្រោះនៅពេលឃាត់ខ្លួន នគរបាលបានយកទូរស័ព្ទ របស់ក្រុមគ្រួសារ ជាមួយនឹងប្រាក់ គ្រឿងអលង្ការ និងវត្ថុផ្សេងៗទាំងអស់ដែលមិនពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលបានចោទប្រកាន់។ ក្រុមគ្រួសាររបស់នាងអាចនិយាយតាមទូរស័ព្ទជាមួយនាងបានម្តងម្កាលប៉ុណ្ណោះ ដោយប្រើប្រាស់ទូរស័ព្ទអ្នកជិតខាង។

នៅសវនាការជំនុំជម្រះ កញ្ញាត្រូវបានដាក់ទោសអោយជាប់ពន្ធនាគារ ២ឆ្នាំ ជាមួយនឹងការព្យួរទោស ១ឆ្នាំ។ ស្វាមីរបស់នាងត្រូវបានដាក់ទោសអោយជាប់ពន្ធនាគារ ៤ឆ្នាំ ជាមួយនឹងការព្យួរទោស ១ឆ្នាំ។ អ្នកទាំងពីរមិនមានមេធាវីដើម្បីតំណាងឲ្យពួកគេទេ ហើយដោយសារតែក្រុមគ្រួសារមិនត្រូវបានផ្តល់ដំណឹងទុកជាមុនអំពីសវនាការជំនុំជម្រះ ដូច្នេះអ្នកទាំងនោះមិនអាចចូលរួមបានឡើយ និងបានត្រឹមតែដឹងដំណឹងពីសេចក្តីសម្រេចរបស់សាលក្រមតាមរយៈទូរស័ព្ទនៅពេលក្រោយប៉ុណ្ណោះ។

កញ្ញានឹងត្រូវបានដោះលែងនៅខែ កក្កដា ឆ្នាំ ២០១៥ និងសង្ឃឹមថានឹងត្រលប់ទៅផ្ទះវិញភ្លាមៗ ដើម្បីជួបជុំកូនរបស់នាង និងជួយសម្រាលសំពាធលើម្តាយរបស់នាង។ ទោះជាយ៉ាងណាក៏ដោយ ការដោះលែងតាមពេលវេលាត្រឹមត្រូវទំនងជាមិនអាចកើតឡើង ដោយតែព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍តវ៉ានិងការដាក់ទោសរបស់នាង ហើយរហូតមកដល់ពេលនេះ នាងមិនបានឮអ្វីទាំងអស់ថាតើបណ្តឹងឧទ្ធរណ៍តវ៉ានេះនឹងធ្វើឡើងនៅពេលណា។[១១]

[១១] នៅកម្ពុជា ប្រសិនបើព្រះរាជអាជ្ញាប្តឹងតវ៉ានិងការដាក់ទោស អ្នកទោសត្រូវតែបន្តនៅក្នុងការឃុំឃាំងដើម្បីរង់ចាំសវនាការបណ្តឹងតវ៉ា ទោះបីជារយៈពេលជាប់ឃុំឃាំងរបស់ពួកគេបានបន្លាយពេលរហូតដល់ហួសថ្ងៃផុតកំណត់នៃ ការជាប់ទោសដើមរបស់ពួកគេក៏ដោយ។ ទោះបីជាត្រូវបានសម្រេចអោយរួចខ្លួនដោយតុលាការនៃសាលាដំបូង អ្នកទាំងនោះដែលត្រូវជាប់ឃុំឃាំងបណ្តោះអាសន្នត្រូវតែបន្តនៅក្នុងពន្ធនាគារ ប្រសិនបើព្រះរាជអាជ្ញាសម្រេចចិត្តប្តឹងតវ៉ានិងការសម្រេចអោយរួចខ្លួននេះ។



កូនស្រីរបស់កញ្ញា អាយុ១៣ឆ្នាំ ខែកុម្ភៈ ឆ្នាំ២០១៥

# សិទ្ធិក្នុងការទាក់ទងទៅគ្រួសារ

នៅក្នុងរបាយការណ៍ថ្មីមួយ[១២] អង្គការ លីកាដូ បានកត់សម្គាល់ថា ទំនាក់ទំនងទៀងទាត់ជាមួយគ្រួសារ និងមិត្តភក្តិ គឺមានសារៈសំខាន់ណាស់ សំរាប់សុខភាពផ្លូវចិត្តរបស់អ្នកជាប់ពន្ធនាគារ ហើយវាដើរតួនាទីសំខាន់មួយ ក្នុងការបញ្ចូលអ្នកទោសចូលទៅក្នុងសង្គមគ្រួសារ និងសហគមន៍វិញ។ នៅកម្ពុជា អ្នកទៅសួរសុខទុក្ខនៅពន្ធនាគារ គឺជាប្រភពដ៏សំខាន់តែមួយគត់នៃចំណីអាហារបំប៉ន ថ្នាំពេទ្យ និងជំនួយហិរញ្ញវត្ថុ។

ខណៈពេលដែលអ្នកជាប់ពន្ធនាគារទាំងអស់ និងគ្រួសាររបស់អ្នកទាំងនោះ មានសិទ្ធិដើម្បីទំនាក់ទំនងរវាងគ្នាទៅវិញទៅមក ដែលរួមទាំងការមកសួរសុខទុក្ខដោយផ្ទាល់ ទន្ទឹមនឹងនេះក្រុមមួយចំនួនអាចនឹងងាយទទួលរងផលប៉ះពាល់ ដែលផ្ទុយពីសិទ្ធិរបស់អ្នកទាំងនោះ នៅពេលសួរសុខទុក្ខ ហើយទំនាក់ទំនងក្នុងទម្រង់ផ្សេងៗទៀតត្រូវបានបដិសេធ ឬហាមឃាត់។ ម្តាយ និងកូនគឺជាឧទាហរណ៍ជាក់ស្តែងមួយ ហើយដោយសារតែចរិតលក្ខណៈនៃទំនាក់ទំនងរបស់ពួកគេ វិធានការពិសេសត្រូវតែដាក់អនុវត្ត ដើម្បីជួយសម្រួលទំនាក់ទំនងដែលទៀងទាត់ និងមិនមានការរារាំង។

គួរអោយសោកស្តាយ នៅកម្ពុជា សិទ្ធិនៃការទទួលបានការសួរសុខទុក្ខ និងការហៅទូរស័ព្ទ គឺពឹងផ្អែកលើស្ថានភាពហិរញ្ញវត្ថុ។ អ្នកសួរសុខទុក្ខត្រូវការបង់ប្រាក់សំរាប់ការសួរសុខទុក្ខម្តងៗ ហើយការទាមទារតម្លៃប្រែប្រួលទៅតាមរយៈពេលនៃការសុខទុក្ខ ទីតាំងជួបថ្ងៃនៃការសួរសុខទុក្ខ និងតាមការសង្កេតមើលនៃសមត្ថភាពហិរញ្ញវត្ថុរបស់អ្នកសួរសុខទុក្ខ។

តម្លៃធម្មតា ដែលបានលើកឡើងដោយអ្នកជាប់ពន្ធនាគារ និងគ្រួសារ គឺពីចន្លោះ ២,៥០ដុល្លារ ទៅ ៥,០០ ដុល្លារ សំរាប់ការសួរសុខទុក្ខ ១៥នាទី នៅខាងមុខរបារដែក ហើយអាចឡើងដល់ ១០ដុល្លារ សំរាប់ការជួបនៅក្នុងបរិវេណពន្ធនាគារ និង ១៥ ដុល្លារ ឬច្រើនជាងនេះសំរាប់ការជួបជាឯកជន។ លទ្ធផលរកឃើញរបស់អង្គការលីកាដូ បានបង្ហាញថាគ្រួសាររបស់ស្ត្រីជាច្រើននាក់ជាញឹកញាប់មិនមានលទ្ធភាពបង់ប្រាក់ សំរាប់ការសួរសុខទុក្ខរយៈពេលវែង ឬ ដោយផ្ទាល់នោះទេ ហើយអ្នកសួរសុខទុក្ខជាច្រើនបានធ្វើដំណើរជាច្រើនម៉ោង ដើម្បីត្រឹមតែការសួរសុខទុក្ខខាងក្រោយរបារដែករយៈពេល ១០ ឬ ១៥នាទីប៉ុណ្ណោះ។

សូម្បីតែអ្នកដែលបងប្រាក់សំរាប់ការសួរសុខទុក្ខ ដែលប៉ះពាល់គ្នាបាន មិនដែលទទួលបានឱកាសជួបជាឯកជនទាល់តែសោះ ដោយការសួរសុខទុក្ខជាធម្មតាធ្វើឡើងដោយមានវត្តមានឆ្មាំគុក និងគ្រួសារដទៃទៀត។ ក្នុងករណីដែលសមាជិកគ្រួសារច្រើនជាងម្នាក់នៅក្នុងពន្ធនាគារ អ្នកសួរសុខទុក្ខជាញឹកញាប់ត្រូវអោយបង់ប្រាក់ទ្វេដង ទោះបីវាសំរាប់កុមារម្នាក់ដើម្បីសួរសុខទុក្ខឪពុកនិងម្តាយរបស់គេដែលបានជាប់ពន្ធនាគារក៏ដោយ។ ទូរស័ព្ទចេញពីពន្ធនាគារក៏មានការពិបាកសំរាប់អ្នកទោសមួយចំនួនផងដែរ ដោយសារអ្នកទោសទាំងនោះតែងតែត្រូវការបង់ប្រាក់អោយឆ្មាំគុក ដើម្បីប្រើប្រាស់ទូរស័ព្ទដៃរបស់គេ។

ដោយសារតែអ្នកទោសជាច្រើននៅកម្ពុជា ដែលរួមទាំងអ្នកទោសជាស្ត្រីភាគច្រើន គឺមកពីគ្រួសារក្រីក្រ ដូច្នេះតំលៃសួរសុខទុក្ខជាញឹកញាប់គឺមិនអាចលៃលកបាន ជាពិសេស នៅពេល គិតរួមទាំងការចំណាយផ្សេងៗ ដូចជា ការធ្វើដំណើរ ការស្នាក់នៅ និងការឈប់សម្រាកពីការងារ។ ជាលទ្ធផល គ្រួសារជាច្រើនអាចទៅសួរសុខទុក្ខបានត្រឹមតែម្តងម្កាលប៉ុណ្ណោះ ហើយអ្នកផ្សេងទៀតមិនអាចធ្វើបានទាល់តែសោះ។

"ស្វាមីរបស់ខ្ញុំបានមកសួរសុខទុក្ខជាមួយនិងកូនប្រុសខ្ញុំអាយុ ១២ឆ្នាំ បានពីរដង។ គាត់អាចមកបានតែថ្ងៃចុងសប្តាហ៍ទេ ពីព្រោះគាត់មិនអាចឈប់សម្រាកពីការងារបាន។ ពួកគាត់ត្រូវចំណាយពេលវេលាបួន ឬប្រាំម៉ោង និង លុយ ៥០.០០០ រៀលជិះឡានក្រុង ដើម្បីមកដល់ពន្ធនាគារ។ ប្រសិនបើពួកគាត់បង់លុយ ១០.០០០ រៀល ខ្ញុំអាចជួបពួកគាត់បានត្រឹមតែ ១៥នាទីទេ។ ហើយម្យ៉ាងទៀតពួកយើងគ្មានភាពឯកជននោះទេ។"

ក្នុងចំណោមពន្ធនាគារ ១៤ កន្លែង ដែលអង្គការ លីកាដូ បានស្ទង់មតិមានតែពន្ធនាគារពីរប៉ុណ្ណោះបានរាយការណ៍អំពីការរៀបចំពិសេសសំរាប់ការសួរសុខទុក្ខរបស់កុមារ។ ពន្ធនាគារទាំងពីរបាននិយាយថាមិនដូចជាអ្នកសួរសុខទុក្ខផ្សេងទៀត កុមារអាចទទួលបានការសួរសុខទុក្ខប៉ះពាល់រាងកាយបានជាមួយនិងម្តាយរបស់ពួកគេ។ ពន្ធនាគារទីបីបានរាយការណ៍ថានៅពេលដែលកុមារម្នាក់មកសួរសុខទុក្ខម្តាយរបស់គេ តំលៃសួរសុខទុក្ខស្តង់ដារ ត្រូវបានអនុគ្រោះអោយចាប់តាំងពីដើមខែមករា ឆ្នាំ ២០១៥ ហើយពន្ធនាគារទីបួនបានកត់សម្គាល់ថា កុមារដែលធ្លាប់រស់នៅក្នុងពន្ធនាគារជាមួយម្តាយ ត្រូវបានអនុគ្រោះពីការបង់ប្រាក់សួរសុខទុក្ខ។

ការដាក់កំណត់តម្លៃសួរសុខទុក្ខនៅពន្ធនាគារ និងតម្លៃទូរស័ព្ទខ្ពស់ មានន័យថា អ្នកជាប់ពន្ធនាគារដែលក្របំផុតត្រូវបានបដិសេធអំពីសិទ្ធិដើម្បីទំនាក់ទំនងជាមួយគ្រួសាររបស់ពួកគេ ហើយការធ្វើបែបនេះ គឺផ្ទុយពីការទទួលខុសត្រូវរបស់រដ្ឋបាលពន្ធនាគារ

[១២] "Rights at a Price: Life inside Cambodia's Prisons" a LICADHO report, January 2015, available at: http://www.licadho-cambodia.org/collection/25/life_inside_cambodia_prison

ដែលធានាថាទំនាក់ទំនងគ្រួសារត្រូវបានរក្សាស្ថេរភាព និងអភិវឌ្ឍន៍ក្នុងកំឡុងពេលនៃការជាប់ពន្ធនាគារ។ ប្រសើរជាងការធ្វើឲ្យទំនាក់ទំនងគ្រួសារមានការពិបាក អាជ្ញាធរពន្ធនាគារគួរដាក់ឲ្យអនុវត្តនូវការរៀបចំ ដែលអនុញ្ញាតអោយមានការទំនាក់ទំនងទៅគ្រួសារដែលល្អបំផុត។ ទាំងនេះគួរតែរួមមានទាំងវិធានការដែលអាចជួយសម្រួលការបន្តចំណងទំនាក់ទំនងរវាងម្តាយ និងកូនផង។

"ចាប់តាំងពីការឃាត់ខ្លួនរបស់ខ្ញុំ ខ្ញុំបានដាច់ទំនាក់ទំនងទាំងស្រុងជាមួយក្រុមគ្រួសារខ្ញុំ។ មិនមានអ្នកណាមកសួរសុខទុក្ខ ឬក៏ទូរស័ព្ទមកខ្ញុំទាល់តែសោះ។ខ្ញុំអត់មានព័ត៌មានអំពីអ្វីៗដែលកើតឡើងចំពោះកូនរបស់ខ្ញុំទាំងអស់ទេ។"

# សិទ្ធិទទួលបានព័ត៌មាន

នេះគឺជាសិទ្ធិមូលដ្ឋានរបស់អ្នកជាប់ឃុំឃាំងទាំងអស់ ក្នុងការទទួលបានឱកាស ដើម្បីផ្តល់ដំណឹងដល់ក្រុមគ្រួសាររបស់ពួកគេអំពីទំតាំងរបស់ពួកគេអោយកាន់តែឆាប់។ សិទ្ធិនេះត្រូវតែដាក់ឲ្យអនុវត្តនៅពេលណាដែលបុគ្គលនោះត្រូវបានបញ្ជូនទៅកន្លែងឃុំឃាំងមួយទៀត ដែលរួមទាំងនៅពេលដែលបុគ្គលនោះត្រូវបានបញ្ជូនពីប៉ុស្តិ៍នគរបាលទៅពន្ធនាគារ។ ការទទួលបានព័ត៌មានទាន់ពេលវេលាអំពីទីតាំងរបស់បុគ្គលជាប់ឃុំឃាំង គឺមានសារៈសំខាន់ជាពិសេសនៅក្នុងករណីដែលបុគ្គលនោះមានការទទួលខុសត្រូវ ចំពោះសមាជិកក្រុមគ្រួសារដូចជាកូននៅតូចៗ។

គួរអោយសោកស្តាយ ស្ត្រីជាច្រើននាក់ដែលត្រូវបានសម្ភាសបានប្រាប់ អង្គការ លីកាដូ ថាពួកគេមិនអាចទាក់ទងជាមួយក្រុមគ្រួសារពួកគេបានទេ នៅពេលដែលពួកគេត្រូវបានឃាត់ខ្លួនដំបូង ឬនៅពេលដែលពួកគេត្រូវបានបញ្ជូនទៅពន្ធនាគារ ពីព្រោះពួកគេមិនមានសិទ្ធិប្រើប្រាស់ទូរស័ព្ទ មិនមានលទ្ធភាពហៅទូរស័ព្ទ ឬពីព្រោះក្រុមគ្រួសាររបស់ពួកគេ មិនអាចមកសួរសុខទុក្ខពួកគេបាន។ ដូចគ្នានេះដែរ អង្គការលីកាដូបានរកឃើញថាក្រុមគ្រួសារជាច្រើនមិនត្រូវបានផ្តល់អោយនូវព័ត៌មាន អំពីស្ថានភាពផ្លូវច្បាប់ សុខភាព និងព័ត៌មានសំខាន់ៗផ្សេងៗទៀតរបស់ម្តាយនោះទេ។

អង្គការ លីកាដូ បានឮករណីដែលកុមារបានដឹងពីការឃុំឃាំងរបស់ម្តាយពួកគេតាមរយៈទូរទស្សន៍ ហ្វេសប៊ុក (Facebook) ឬអ្នកជិតខាង ដែលបានទៅសួរសុខទុក្ខអ្នកជាប់ពន្ធនាគារផ្សេងទៀតនៅក្នុងពន្ធនាគារតែមួយ។ អង្គការលីកាដូបាននិយាយជាមួយក្រុមគ្រួសារដែលមិនអាចចូលរួម សវនាការជំនុំជម្រះ ពីព្រោះពួកគេមិនបានទទួលព័ត៌មានអំពីកាលបរិច្ឆេទនៃសវនាការជំនុំជម្រះ ហើយអង្គការ លីកាដូ ក៏បាននិយាយជាមួយអ្នកដែលមិនដឹងថា អ្នកជាប់ឃុំឃាំងទទួលបានសវនាការជំនុំជម្រះ និងត្រូវបានកាត់ក្តីអោយជាប់ទោសរួចរាល់ទៅហើយនោះទេ។ អង្គការ លីកាដូ និយាយជាមួយអ្នកជាប់ពន្ធនាគារផ្សេងទៀត ដែលមិនបានដឹងអំពីរយៈពេលនៃការជាប់ពន្ធនាគារ ឬកាលបរិច្ឆេទនៃការដោះលែងរបស់ម្តាយ។

ខណៈពេលដែល ក្រុមគ្រួសារពេលខ្លះលាក់ទុកព័ត៌មានមិនអោយកុមារដឹង ទន្ទឹមនឹងនេះកង្វះខាតព័ត៌មានអំពីនិតិវិធីតុលាការ និងអំពីស្ថានភាពរបស់ម្តាយនៅក្នុងពន្ធនាគារ ក៏អាចធ្វើអោយកុមារមួយចំនួនមានអារម្មណ៍ច្របូកច្របល់ថា តើមានអ្វីកើតឡើងចំពោះម្តាយពួកគេ តើហេតុអ្វីបានជាម្តាយពួកគេមិននៅផ្ទះទាល់តែសោះ ឬតើពេលណាម្តាយពួកគេមកផ្ទះវិញ។

នៅពេលខ្លះ សូម្បីតែអ្នកជាប់ពន្ធនាគារខ្លួនឯងក៏មិនទទួលបានព័ត៌មានទាន់ពេលវេលា អំពីដំណើរការផ្លូវច្បាប់នៃរឿងក្តីរបស់ខ្លួនដែរ ដូចជាកាលបរិច្ឆេទនៃសវនាការជំនុំជម្រះសវនាការ បណ្តឹងតវ៉ា និងការជូនដំណឹងអំពីការប្តឹងតវ៉ារបស់ព្រះរាជអាជ្ញា។ គួរ អោយសោកស្តាយ បញ្ហាទាំងនេះក៏កើតឡើងចំពោះអ្នកជាប់ពន្ធនាគារមួយចំនួនដែលបានបង់ប្រាក់សេវាកម្មមេធាវីផងដែរ។ មានស្ត្រី មួយចំនួនបានប្រាប់អង្គការលីកាដូថា ពួកគេមិនដែលទទួលបានព័ត៌មានអំពីសិទ្ធិរបស់ពួកគេក្នុងការប្តឹងតវ៉ា ឬអំពីដំណើរការដែលពួកគេអាចដាក់ស្នើសុំការលើកលែងទោស ឬការបន្ធូរបន្ថយទោសបាននោះ ទេ។

គួរអោយសោកស្តាយ នេះជាករណីភាគច្រើនដែលម្តាយខ្លួនឯងផ្ទាល់ទទួលបានព័ត៌មានតិចតួច ឬគ្មានទាល់តែសោះ អំពីកូនរបស់ពួកគេនៅខាងក្រៅពន្ធនាគារ។ ស្ត្រីមួយចំនួនដែលត្រូវបានសម្ភាសមិនដឹងថាកូននៅទីណា ឬមានអ្វីកើតឡើងចំពោះកូនចាប់តាំងពីការឃាត់ខ្លួនស្ត្រីទាំងនោះ។ ស្ត្រីមួយចំនួនទៀតដឹងត្រឹមតែថាកូននៅទីណា ប៉ុន្តែមិនដឹងថាពួកគេយ៉ាងម៉េចទៅហើយ តើពួកគេនៅតែទៅសាលារៀនដែរឬទេ ឬតើឪពុករបស់ពួកគេមានបានទាក់ទងជាមួយកូនដែរឬទេ។ ហើយក្នុងចំណោមស្ត្រីដែលទទួលបាន ព័ត៌មានស្ត្រីមួយចំនួនទទួលបានព័ត៌មានតាមរយៈជនទីបី ដូចជាអ្នកជាប់ពន្ធនាគារជាមួយ ដែលមានអ្នកមកសួរសុខទុក្ខមកពីភូមិតែមួយ។

" ខ្ញុំចង់ទៅចូលរួមសវនាការជំនុំជម្រះរបស់នាង ដើម្បីអោយដឹងថា មានអ្វីខ្លះកើតឡើង ប៉ុន្តែខ្ញុំមិនមានលទ្ធភាពទៅទេ។ ខ្ញុំមិនដឹងអ្វីទាំងអស់អំពីដំណើរការតុលាការ។ ម្យ៉ាងទៀត ខ្ញុំមិនដែលដឹងថា តុលាការនៅទីកន្លែងណាផង។"



កូនៗរបស់អ្នកជាប់ឃុំក្នុងពន្ធនាគារ ខែមីនា ឆ្នាំ២០១៥

## ករណីសិក្សា៖ សុជាតា

សុជាតាត្រូវបានឃាត់ខ្លួននៅខែមករា ឆ្នាំ ២០១៥។ នាងបានប្រាប់អង្គការលីកាដូថា នាងមិនអាចទាក់ទងក្រុមគ្រួសាររបស់នាងបានទេរហូតដល់ពីរអាទិត្យក្រោយបន្ទាប់ពីការឃាត់ខ្លួនរបស់នាង ដោយសារតែនាង និងក្រុមគ្រួសាររបស់នាងមិនអាចប្រើប្រាស់ទូរស័ព្ទបាន។ ផ្ទុយទៅវិញ កូនរបស់នាងអាយុ ១២ឆ្នាំ អាយុ ៩ឆ្នាំ និងអាយុ ៣ឆ្នាំ បានដឹងអំពីការជាប់ពន្ធនាគាររបស់នាងតាមរយៈហ្វេសប៊ុក (Facebook)។ នៅពេលដែលអង្គការលីកាដូទៅជួបនាង ជាងមួយខែក្រោយពីការជាប់ពន្ធនាគារ កូនរបស់នាងទាំងអស់នៅតែមិនអាចមកសួរសុខទុក្ខនាងបាន ដោយសារតែការធ្វើដំណើរពីផ្ទះរបស់ពួកគេមកពន្ធនាគារត្រូវការចំណាយរយៈពេល ២ម៉ោង ។ នាងបានត្រឹមតែជួបជាមួយនិងកូនរបស់នាងតាមទូរស័ព្ទតែម្តងគត់។

មិនយូរប៉ុន្មានបន្ទាប់ពីនាងត្រូវបានឃាត់ខ្លួន កូនពៅអាយុ ៣ឆ្នាំរបស់សុជាតា ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យរយៈពេលមួយសប្តាហ៍ ដោយគេមានបញ្ហាក្រលៀន។ សុជាតាបានឮអំពីរឿងនេះតាមរយៈអ្នកជាប់ពន្ធនាគារម្នាក់ទៀត ដែលទទួលបានព័ត៌មាននេះពីអ្នកមកសួរសុខទុក្ខម្នាក់ដែលបានព័ត៌មាននេះតាមរយៈស្វាមីរបស់នាង។ សុជាតាបានប្រាប់អង្គការលីកាដូថាអាជ្ញាធរពន្ធនាគារមិនបានផ្តល់ជំនួយអ្វីទាំងអស់ដល់នាងដើម្បីទាក់ទងទៅក្រុមគ្រួសារទេ។ នាងបានហៅទូរស័ព្ទតែមួយដងគត់ដោយប្រើប្រាស់ទូរស័ព្ទដៃខុសច្បាប់របស់អ្នកជាប់ពន្ធនាគារម្នាក់ទៀត។

នៅពេលឃាត់ខ្លួន នគរបាលបានសួរសុជាតាថាតើនាងមានកូនដែរឬទេ ហើយប៉ុន្មាននាក់ ប៉ុន្តែពួកគេមិនបានសួរនាងថាតើកូនទាំងនោះនៅឯណាទេ ឬតើអ្នកណាជាអ្នកមើលថែពួកគេនោះទេ។ នាងប្រាប់អង្គការលីកាដូថា ផ្ទុយទៅវិញគេបានប្រាប់នាងថា "អ្នកគួរតែគិតអំពីកូនរបស់អ្នកនៅពេលដែលអ្នកប្រព្រឹត្តបទល្មើស។" សុជាតាក៏បានប្រាប់អង្គការលីកាដូផងដែរថា នៅពេលឃាត់ខ្លួន នគរបាលបានសរសេរខេត្តទីលំនៅក្នុងឯកសាររបស់នាងមិនត្រឹមត្រូវ ហើយតាមអ្វីដែលនាងដឹង កំហុសនេះមិនទាន់បានកែតម្រូវនោះទេ។

# ការមិនមានជំនួយ

បន្ថែមពីលើការខ្វះខាតព័ត៌មានអំពីផលប៉ះពាល់នៃការជាប់ពន្ធនាគាររបស់ម្តាយទៅលើកូនៗ ភ្លាមនោះអង្គការលីកាដូបានឃើញយ៉ាងច្បាស់នៅពេលធ្វើការស្រាវជ្រាវដំបូង នៅក្នុងបញ្ហាទាំងនេះថាមានបណ្តាញគាំទ្រតិចតួចណាស់ ដើម្បីជួយទៅដល់កូនរបស់អ្នកជាប់ពន្ធនាគារនៅក្នុងកម្ពុជា។ ដូចដែលបានលើកឡើង កុមារដែលមកពីគ្រួសារក្រីក្រ និងភាគច្រើននៅជនបទ កម្រអាចទៅសួរសុខទុក្ខម្តាយរបស់ពួកគេនៅក្នុងពន្ធនាគារ ដោយការចំណាយទាក់ទងនឹងការជាប់ពន្ធនាគារ អាចធ្ងន់ធ្ងរខ្លាំងចំពោះក្រុមគ្រួសារជាច្រើន ក្នុងការរ៉ាប់រង ហើយក្នុងករណីមួយចំនួន លទ្ធភាពរកចំណូលចិញ្ចឹមជីវិតរបស់ក្រុមគ្រួសារទាំងមូល ត្រូវបានបាត់បង់ នៅពេលដែលសមាជិកក្រុមគ្រួសារម្នាក់ជាប់ពន្ធនាគារ។

ប៉ុន្តែលទ្ធផលនៃការស្រាវជ្រាវរបស់អង្គការលីកាដូ បង្ហាញថាត្រឹមតែជំនួយតិចតួច អាចធ្វើអោយមានការខុសប្លែកគ្នា ខ្លាំងក្នុងការរក្សាស្ថេរភាពទំនាក់ទំនងផ្លូវកាយ និងផ្លូវចិត្តរបស់ក្រុមគ្រួសារដែលអាចជួយធានាថាកុមារនឹងបន្តការសិក្សា និងរក្សាដំណើរការមុខរបរជំនួញរបស់ក្រុមគ្រួសារបន្តទៀត។ កត្តាទាំងអស់នេះនឹងធ្វើឲ្យថយចុះ ទៅលើការងាយងាកទៅរកការប្រព្រឹត្តបទល្មើសរបស់សមាជិកគ្រួសារដទៃទៀត និងធ្វើឲ្យថយចុះលើអត្រាប្រព្រឹត្តបទល្មើស ម្តងទៀតរបស់ស្ត្រី នៅពេលដែលអ្នកទាំងនោះត្រូវបានដោះលែងពីពន្ធនាគារ។

" កូនប្រុសអាយុ៥ ឆ្នាំរបស់ខ្ញុំមានជំងឺឆ្កួតជ្រូក។ មុនពេលការចាប់ខ្លួនរបស់ខ្ញុំ ខ្ញុំតែងតែនាំកូនទៅមន្ទីរពេទ្យ សំរាប់ការពិនិត្យមើលទៀងទាត់ និងយកថ្នាំ ប៉ុន្តែឥឡូវកូនខ្ញុំអត់មានថ្នាំបន្តទៀតទេ។ ខ្ញុំគ្មានអ្នកណាអាចនាំកូនខ្ញុំទៅមន្ទីរពេទ្យទៀតទេ។"

# អង្គការជីវិតនៅកម្ពុជា

ដោយបង្កើតឡើងនៅឆ្នាំ២០០៧ អង្គការជីវិតនៅកម្ពុជាផ្តោតលើការផ្តល់ឱកាសដល់សហគមន៍ ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជំនាញ និងចំណេះដឹងដើម្បីធ្វើអោយមានការប្រែប្រួលវិជ្ជមាននៅក្នុងជីវិតរបស់សហគមន៍ និងចាកអោយផុតពីភាពក្រីក្រ។ ដោយមានការិយាល័យកណ្តាលនៅខេត្តសៀមរាប អង្គការជីវិតកម្ពុជាកំពុងប្រតិបត្តិការកម្មវិធីចំនួនបួននៅខេត្តសៀមរាប បន្ទាយមានជ័យ និងឧត្តរមានជ័យ ដែលរួមទាំងកម្មវិធីជីវិតនៅខាងក្រៅពន្ធនាគារ[១៣] (This Life Beyond Bars) ដែលជាកម្មវិធីមួយដែលធ្វើការជាមួយកុមារ ក្រុមគ្រួសារ និងសហគមន៍ដែលប៉ះពាល់ដោយប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។

តាមអ្វីដែលអង្គការលីកាដូបានដឹង ជីវិតនៅកម្ពុជាគឺជាអង្គការតែមួយគត់នៅក្នុងកម្ពុជា ដែលមានកម្មវិធីច្បាស់លាស់ត្រឹមត្រូវ និងយកចិត្តទុកដាក់ក្នុងការទ្រទ្រង់កូន និងគ្រួសាររបស់អ្នកជាប់ពន្ធនាគារ។ ការរកឃើញរបស់អង្គការលីកាដូ គឺដូចទៅនឹងចំណុចព្រួយបារម្ភ ដែលអង្គការនោះបានកំណត់ និងដោះស្រាយតាមរយៈកម្មវិធីទ្រទ្រង់គ្រួសាររបស់ជីវិតនៅខាងក្រៅពន្ធនាគារ ហើយបានបង្ហាញពីតម្រូវការបន្ទាន់ និងបន្តបន្ទាប់នៃគំរោងបែបនេះ។

កម្មវិធីនេះផ្តល់នូវសេវាកម្មគាំទ្រដល់គ្រួសារដែលមានឪពុកឬម្តាយនៅក្នុងពន្ធនាគារ ដោយទប់ស្កាត់ការបែកបាក់កូនពីគ្រួសារដែលមិនចាំបាច់ និងការកសាងក្រុមគ្រួសារអោយល្អប្រសើរឡើងវិញ។ កម្មវិធីជីវិតនៅខាងក្រៅពន្ធនាគារ គាំទ្រអ្នកមើលថែនៃក្រុមគ្រួសារងាយរងគ្រោះ ដើម្បីផ្តល់នូវតម្រូវការចាំបាច់ និងសុខុមាលភាពដល់កុមារ ក្នុងកំឡុងពេលជាប់ពន្ធនាគាររបស់ឪពុកម្តាយអ្នកទាំងនោះ។ កម្មវិធីជីវិតនៅខាងក្រៅពន្ធនាគារ ជួយឲ្យកុមារបន្តស្នាក់នៅក្រោមការថែទាំពីគ្រួសារជិតបំផុតរបស់កុមារ។

គំរោងរបស់ជីវិតនៅខាងក្រៅពន្ធនាគារ កាត់បន្ថយសំពាធទៅលើអ្នកមើលថែរក្សា និងធានាការពារអនាគតរបស់កុមារ ដោយផ្តល់នូវអាហាររូបករណ៍ សកម្មភាពបង្កើតចំណូលរបស់គ្រួសារ និងការផ្តល់សេវាសុខភាព និងករណីអាសន្ន។ បន្ថែមពីលើនេះ ការទៅសួរសុខទុក្ខឪពុកម្តាយនៅក្នុងពន្ធនាគារជារៀងរាល់ខែ ធានាថាទំនាក់ទំនងមូលដ្ឋានរវាងឪពុកម្តាយនិងកូន មិនត្រូវបានកាត់ផ្តាច់។ គំរោងនេះជួយផ្គត់ផ្គង់អ្នកមើលថែទាំ នូវការធានាជាថ្មីដែលពួកគេត្រូវការ និងជួយពង្រឹងសមត្ថភាពពួកគេក្នុងការផ្តល់នូវតម្រូវការសំខាន់ៗដល់កុមារដែលនៅក្នុងការមើលថែទាំរបស់អ្នកទាំងនោះ។

មកដល់បច្ចុប្បន្ន ក្នុងចំណោម ៣១ គ្រួសារ ដែលគាំទ្រដោយគម្រោង ២៤គ្រួសារ បានស្ថិតនៅក្នុងស្ថានភាពដែលនឹងចាប់ផ្តើមឬពង្រឹងបន្ថែមទៅលើសកម្មភាពបង្កើតចំណូល ដែលពួកគេជ្រើសរើស។ ក្នុងចំណោមកុមារ ៨៤នាក់នៃគ្រួសារទាំងនេះ មានកុមារចំនួន

[១៣] http://www.thislifecambodia.org/programs/this-life-beyond-bars

៦០នាក់ ដែលរួមមានកុមារី ៣៥នាក់ផង បានទទួលអាហាររូបករណ៍ ដើម្បីបន្តការសិក្សានៅសាលារដ្ឋ។ ជារៀងរាល់ខែ ជាមធ្យម ៩៣% នៃ គ្រួសារដែលចូលរួមនៅក្នុងគម្រោងនេះ បានយកឱកាសទៅសួរសុខទុក្ខឪពុកម្តាយរបស់អ្នកទាំងនោះ នៅក្នុងពន្ធនាគារ។

## សមាហរណកម្មទៅក្នុងសង្គមគ្រួសារវិញដោយជោគជ័យ

សុខលៀងត្រូវបានចាប់ខ្លួននៅឆ្នាំ ២០១១ និងត្រូវបានដាក់ទោសអោយជាប់ពន្ធនាគាររយៈ ពេលបីឆ្នាំកន្លះ ពីបទល្មើសជួញដូរគ្រឿងញៀន។ នាងមានកូនស្រីបួននាក់ ហើយកូនបីនាក់ មានអាយុ ១៣ឆ្នាំ, ៩ឆ្នាំ និង៥ឆ្នាំ កំពុងរស់នៅក្នុងបន្ទុករបស់នាង នៅពេលដែលនាងត្រូវបានគេចាប់ខ្លួន។

បន្ទាប់ពីការចាប់ខ្លួនរបស់សុខលៀង ក្រុមគ្រួសាររបស់នាងបានសម្រេចចិត្តថា កូនរបស់នាងគួរតែទៅរស់នៅផ្ទះលោកយាយនៅដីមួយកន្លែង ជិតផ្ទះរបស់ក្រុមគ្រួសារ។ ឪពុករបស់ពួកគេគឺជាអ្នកប្រមឹកធ្ងន់ធ្ងរ ដែលមានប្រវត្តិធ្លាប់ប្រើអំពើហិង្សា និងជាញឹកញាប់មិនដែលនៅផ្ទះនោះទេ។ មុនពេលការចាប់ខ្លួនរបស់នាង សុខលៀងធ្វើដំណើរទៅមកព្រំដែន ដែលជាកន្លែងដែលនាងអាចរកការងារធ្វើជាកម្មករនៅកសិដ្ឋានបាន។

ដោយការបាត់បង់ចំណូលរបស់សុខលៀង និងការចំណាយទាក់ទងនឹងការជាប់ពន្ធនាគាររបស់នាង ភ្លាមៗនោះក្រុមគ្រួសាររបស់នាងចាប់ផ្តើមមានវិបត្តិហិរញ្ញវត្ថុ។ ប្អូនប្រុសរបស់សុខលៀងពេលខ្លះអាចផ្ញើប្រាក់ដើម្បីជួយទ្រទ្រង់ក្រុមគ្រួសាររបស់នាង ប៉ុន្តែឃើញថា ពួកគេរឹតតែមិនអាចរកប្រាក់សម្រាប់ការចំណាយការរស់នៅប្រចាំថ្ងៃ និងការចំណាយលើការសិក្សាបានទៀតនោះទេ។

បន្ទាប់ពីសុខលៀង ជាប់ពន្ធនាគាររយៈពេល ២ខែមក កូនស្រីអាយុ ១៣ឆ្នាំរបស់នាងបានឈប់រៀន ពីព្រោះនាងមានការខ្មាសអៀនដោយសារគ្មានប្រាក់ ឬយានជំនិះទៅសាលារៀន។ បន្ទាប់ពីត្រលប់ទៅសិក្សាវិញមួយរយៈ នៅអាយុ ១៦ឆ្នាំ នាងបានឈប់រៀនម្តងទៀត ហើយបានចាកចេញពីផ្ទះ ដើម្បីទៅរកការងារធ្វើនៅប្រទេសថៃ ជាទីកន្លែងដែលប្អូនប្រុសរបស់សុខលៀងកំពុងរស់នៅ។ កូនស្រីរបស់នាងនោះបច្ចុប្បន្ន ធ្វើការជាអ្នកបម្រើតាមផ្ទះនៅឯប្រទេសថៃ ដែលនាងនិយាយថា នាងរកប្រាក់បានគ្រប់គ្រាន់ត្រឹមតែសម្រាប់រស់ប៉ុណ្ណោះ។

អង្គការជីវិតនៅកម្ពុជាចាប់ផ្តើមជួយគ្រួសារនេះនៅខែមីនា ឆ្នាំ២០១៣ ដោយជួយផ្គត់ផ្គង់កូនតូចៗទាំងពីរនាក់របស់សុខលៀង បានបន្តការសិក្សា។ អង្គការជីវិតនៅកម្ពុជាបានផ្តល់នូវជំនួយផ្នែកថែទាំសុខភាព និងជំនួយគ្រាអាសន្ន។ សំខាន់បំផុត អង្គការក៏បានផ្តល់អោយគ្រួសារនូវការចំណាយលើការធ្វើដំណើរ ដើម្បីអោយកុមារអាចទៅសួរសុខទុក្ខម្តាយរបស់អ្នកទាំងនោះនៅពន្ធនាគារម្តងក្នុងមួយខែ។ អង្គការក៏បានធ្វើអន្តរាគមន៍ជាមួយនឹងអាជ្ញាធរពន្ធនាគារផងដែរ ដូច្នេះគ្រួសារមិនចាំបាច់ត្រូវបង់ប្រាក់សួរសុខទុក្ខណាមួយឡើយ ហើយអង្គការបានផ្តល់អោយសុខលៀង នូវការចំណាយថ្លៃធ្វើដំណើរត្រលប់ទៅផ្ទះវិញនៅពេលដែលនាងត្រូវបានគេដោះលែង។

គ្រួសារនេះក៏ទទួលបានជំនួយរយៈពេលវែងក្នុងទំរង់ជាកម្មវិធីបង្កើតចំណូល។ អង្គការជីវិតនៅកម្ពុជា បានជួយគ្រួសារនេះក្នុងការរៀបចំកសិដ្ឋានចិញ្ចឹមជ្រូកខ្នាតតូចមួយ ដែលឥឡូវនេះទទួលបានជោគជ័យ ហើយអង្គការបានផ្តល់អោយពួកគេ នូវការបណ្តុះបណ្តាលអំពីរបៀបថែទាំជ្រូក។ សុខលៀងដែលត្រូវបានដោះលែងនៅខែមករា ឆ្នាំ២០១៥ ឥឡូវនេះនាងបានទទួលយកការទទួលខុសត្រូវចំបងក្នុងការថែទាំសត្វ ដែលជួយបង្កើនប្រាក់ចំណូលរបស់ក្រុមគ្រួសារ ហើយនេះក៏អនុញ្ញាតអោយនាងនៅផ្ទះ និងចំណាយពេលវេលាច្រើនដើម្បីមើលថែកូនរបស់នាងផងដែរ។

ម្តាយរបស់សុខលៀងបានប្រាប់អង្គការលីកាដូថា "មុនពេលដែលពួកគាត់ (ជីវិតនៅកម្ពុជា) បានជួយយើង យើងមានបន្ទុកធ្ងន់ណាស់។ នេះពិតជាពិបាកណាស់។ ពេលខ្លះខ្ញុំអត់មានអាហារគ្រប់គ្រាន់សំរាប់ខ្លួនឯងផង ហើយខ្ញុំត្រូវមើលថែទាំក្មេងបីនាក់ទៀត។ ពួកយើងអត់មានលុយដើម្បីបញ្ជូនកូនទាំងនោះទៅសាលារៀនទេ ហើយអ្នកទាំងនោះអត់មានអាហារទទួលទានគ្រប់គ្រាន់ ឬសំលៀកបំពាក់គ្រប់គ្រាន់ទេ។ ដូច្នេះស្ទើរតែមិនអាចទៅរួចសំរាប់ពួកយើងទៅសួរសុខទុក្ខសុខលៀងនៅក្នុងពន្ធនាគារ។"

អង្គការ ជីវិតនៅកម្ពុជា
THIS LIFE CAMBODIA
A SUSTAINABLE COMMUNITY DEVELOPMENT INITIATIVE

# ដំណោះស្រាយរយៈពេលវែងដែលងាយស្រួលសម្រេចបាន

ការអនុវត្តបច្ចុប្បន្នទាក់ទងនឹងការឃាត់ខ្លួន និងការឃុំឃាំងរបស់ម្តាយ គឺមានលក្ខណៈខុសប្លែកទៅនឹងច្បាប់ និងនីតិវិធី ដែលផ្តល់នូវវិធីសាស្ត្រផ្សេងៗក្រៅពីការឃុំឃាំង ជាពិសេសនៅក្នុងករណីដែលស្ត្រីមានកូន ឬស្ត្រីមានផ្ទៃពោះ។

នៅពេលដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន អំពាវនាវអោយក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ស្វែងរកនូវដំណោះស្រាយរយៈពេលវែង ចំពោះបញ្ហាអ្នកទោសស្ត្រីដែលមានកូននៅក្នុងពន្ធនាគារ អង្គការលីកាដូបានឆ្លើយតបដោយកត់សម្គាល់ថា នៅក្នុងប្រទេសកម្ពុជាមាននីតិវិធីសំរាប់ជួយដោះស្រាយបែបនេះរួចទៅហើយ។[១៤] អង្គការ លីកាដូ ក៏បានកត់សម្គាល់ផងដែរថា នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានជំហានមួយចំនួនត្រូវបានអនុវត្តរួចទៅហើយក្នុងការលើកស្ទួយការធ្វើនីតិសម្បទាការជាប់ពន្ធនាគារ ជម្រើសផ្សេងក្រៅពីការឃុំឃាំងបណ្តោះអាសន្នរង់ចាំសវនាការ និងការដាក់ទោសក្រៅឃុំ។ តែគួរអោយសោកស្តាយការអនុវត្តកំនែទម្រង់នេះមានការយឺតយ៉ាវ។

ដូចដែលបានចែងច្បាស់លាស់ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ជាគោលការណ៍ បុគ្គលត្រូវបានចោទប្រកាន់គួរតែនៅមានសេរីភាព។[១៥] ការឃុំឃាំងបណ្តោះអាសន្នរង់ចាំសវនាការគួរតែត្រូវធ្វើឡើងចំពោះតែករណីពិសេស និងតែករណីណាដែលបទឧក្រិដ្ឋ ឬបទល្មើសមជ្ឈឹម ពាក់ព័ន្ធនឹងការដាក់ទោសរយៈពេលមួយឆ្នាំ ឬ ច្រើន។[១៦]

ចំពោះការសម្រេចចិត្តលើការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ គោលការណ៍ណែនាំរបស់ក្រសួងយុត្តិធម៌បានចែងថា ចៅក្រមស៊ើបអង្កេតជានិច្ចកាល គួរតែសាកសួរព័ត៌មានទាំងអស់ ទាក់ទងនិងបុគ្គលត្រូវបានចោទប្រកាន់ មុនពេលសម្រេចចិត្តថាតើគួរធ្វើការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការដែរឬទេ។ នេះគួរតែរួមទាំងថាតើបុគ្គលចោទប្រកាន់គឺជាស្ត្រីមានផ្ទៃពោះ ឬស្ត្រីមានកូនតូច។ គោលការណ៍ណែនាំនេះបានបញ្ជាក់ច្បាស់លាស់ថា ប្រសិនបើស្ត្រីមានផ្ទៃ ពោះ ឬប្រសិនបើស្ត្រីមានកូន ហើយមិនមានការរៀបចំមើលថែកុមារសមស្របទេ ការឃុំឃាំងបណ្តោះអាសន្នរង់ចាំសវនាការមិនគួរត្រូវបានធ្វើឡើងទេ លុះត្រាតែចាំបាច់បំផុត។

គួរអោយសោកស្តាយ លទ្ធផលស្រាវជ្រាវរបស់ អង្គការលីកាដូ បង្ហាញអោយឃើញថា គោលការណ៍ណែនាំរបស់ក្រសួងយុត្តិធម៌គឺមិនត្រូវបានអនុវត្តតាមអោយបានត្រឹមត្រូវ ឬដាប់លាប់នោះទេ។ ជាការពិត ស្ត្រីភាគច្រើនដែលត្រូវបានសម្ភាសបានរាយការណ៍ថា នគរបាល និងមន្ត្រីតុលាការមិនបានសាកសួរអ្នកទាំងនោះថាតើពួកគេមានកូនឬក៏មិនមាន នៅពេលធ្វើការឃាត់ខ្លួន ឬនៅកំឡុងពេលការស្តាប់សវនាការលើការឃុំខ្លួនបណ្តោះអាសន្ន មុនពេលជំនុំជម្រះ។ ទោះបីជាអ្នកទាំងនោះបានសាកសួរក៏ដោយ ក៏ជាញឹកញាប់អ្នកទាំងនោះមិនដែលសួរថាតើអ្នកណាអាចមើលថែកូន នៅពេលឃាត់ខ្លួន និងពេលឃុំឃាំងកើតឡើង នោះដែរ។

នៅពេលណាដែលតុលាការធ្វើការសម្រេចចិត្តបញ្ជូន ជនសង្ស័យទៅឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ យោងតាមលិខិតចេញដោយក្រសួងយុត្តិធម៌នៅដើមឆ្នាំ ២០១៤ តម្រូវអោយអ្នកទាំងនោះត្រូវតែបង្ហាញថា ពួកគេបានពិចារណាយ៉ាងប្រុងប្រយ័ត្ន អំពីអង្គហេតុពាក់ព័ន្ធទាំងអស់។ អ្នកទាំងនោះគួរតែពន្យល់អោយច្បាស់លាស់ពីមូលហេតុមួយណានៃមូលហេតុទាំងប្រាំមួយ នៃការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ដូចដែលបានចែងនៅក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលត្រូវបានដាក់ឲ្យអនុវត្តដើម្បីធានាថា ការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ គឺត្រូវបានប្រើប្រាស់ជាជម្រើសចុងក្រោយប៉ុណ្ណោះ។ ប៉ុន្តែ តាមព័ត៌មានទទួលបានដោយអង្គការលីកាដូ បង្ហាញថាមានតែតុលាការមួយចំនួនប៉ុណ្ណោះដែលកំពុងប្រើបាស់ទម្រង់បែបបទថ្មីនេះ ហើយតុលាការទាំងនោះជាញឹកញាប់នៅតែមិនបានយកចិត្តទុកដាក់ក្នុងការផ្តល់នូវមូលហេតុរឹងមាំមួយចំពោះការសម្រេចចិត្តរបស់តុលាការទាំងនោះ។

នៅពេលដាក់ទោស អង្គការលីកាដូជឿជាក់ថាបុគ្គលជាច្រើននាក់ ដែលត្រូវបានកាត់ក្តីអោយជាប់ពន្ធនាគារពីបទល្មើសស្រាលជាពិសេសគឺម្តាយនិងស្ត្រីមានផ្ទៃពោះ គួរតែត្រូវបានពិចារណានូវទោសមិនជាប់ពន្ធនាគារផ្សេងៗ ដែលចែងរួចទៅហើយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងក្រមព្រហ្មទណ្ឌ ដូចជានៅក្រោមការត្រួតពិនិត្យរបស់តុលាការ ការព្យួរទោស និងការបម្រើការងារសហគមន៍ជាដើម។ ប៉ុន្តែ ជម្រើសផ្សេងក្រៅពីទោសជាប់ពន្ធនាគារ គឺកម្រត្រូវបានយកមកពិចារណាណាស់ នៅពេលដាក់ទោស ហើយនៅមានការមិនទុកចិត្ត និងសង្ស័យក្នុងការប្រើប្រាស់វិធានការដាក់ឲ្យនៅក្រៅឃុំបណ្តោះអាសន្នរង់ចាំសវនាការ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ រាជរដ្ឋាភិបាលបានរៀបចំ

---

[១៤] មើល http://www.licadho-cambodia.org/pressrelease.php?perm=375 and http://www.licadho-cambodia.org/pressrelease.php?perm=379

[១៥] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២០៣ និង ២០៤

[១៦] ផ្អែកទៅលើមាត្រា ២០៥ នៃនីតិវិធីព្រហ្មទណ្ឌ ការឃុំខ្លួនបណ្តោះអាសន្ន គួរតែត្រូវធ្វើឡើងលុះត្រាតែចាំបាច់ដើម្បីបញ្ឈប់បទល្មើស ឬ ទប់ស្កាត់បទល្មើសកុំអោយកើតឡើងម្តងទៀត, ទប់ស្កាត់ការយាយីណាមួយលើសាក្សី ឬជនរងគ្រោះ ឬទប់ស្កាត់ការឃុបឃិតណាមួយរវាងបុគ្គលត្រូវបានចោទប្រកាន់ និងអ្នកផ្សំគំនិត, ការពារភស្តុតាង ឬវត្ថុតាង, ធានាថាបុគ្គលត្រូវបានចោទប្រកាន់មានវត្តមានក្នុងដំណាក់កាលជម្រះក្តីរបស់គេ, ការពារសុវត្ថិភាពរបស់បុគ្គលត្រូវបានជាប់ប្រកាន់ឬដើម្បីការពារសណ្តាប់ធ្នាប់សាធារណៈពីបញ្ហាណាមួយបង្កដោយបទល្មើស។

ក្រុមការងារទៅលើជម្រើសដាក់ទោសផ្សេងៗក្រៅពីទោសពន្ធនាគារ។ ក្រុមការងារនោះ បានចេញសារាចរចំនួនបី នៅដើមខែមករា ឆ្នាំ ២០១៤ ក្នុងគោលបំណងផ្តល់ឲ្យមន្ត្រីតុលាការនូវការណែនាំបន្ថែម អំពីការអនុវត្តន៍ការដាក់ទោសក្រៅឃុំផ្សេងៗ។

គោលបំណងគឺដើម្បីធានាថា ចៅក្រមស៊ើបអង្កេត និង ព្រះរាជអាជ្ញា ប្រតិបត្តិតាមគោលការណ៍ច្បាប់ ដោយពិនិត្យអោយគ្រប់ជ្រុងជ្រោយទៅក្នុងចរិតលក្ខណៈនៃបទល្មើស អត្តចរិត និងស្ថានភាពផ្ទាល់ខ្លួនរបស់បុគ្គលត្រូវបានចោទប្រកាន់ មុនពេលធ្វើការសម្រេចចិត្តថាតើ ការដាក់ទោសជាប់ពន្ធនាគារជា គឺជាការចាំបាច់ដែរ ឬទេ។ ប៉ុន្តែ អង្គការ លីកាដូ មិនទាន់ឃើញមានភស្តុតាងណាមួយដែលបង្ហាញពីលទ្ធផលវិជ្ជមាន ឬការប្តេជ្ញាពិតប្រាកដណាមួយក្នុងការធ្វើអោយមានការរីកចំរើនដ៏រឹងមាំនៅឡើយ។

# ការបញ្ឈប់ការឃុំខ្លួនដែលផ្តល់ផលអាក្រក់ និងមិនចាំបាច់

សម្រាប់ជាដំណោះស្រាយដ៏មានអត្ថន័យ និងយូរអង្វែងចំពោះបញ្ហានៅក្នុងពន្ធនាគារកម្ពុជា អង្គការ លីកាដូ នៅតែស្នើសុំឲ្យមានការផ្លាស់ប្តូរជាមូលដ្ឋាន ចេញពីការប្រើប្រាស់គ្រប់ពេលវេលានូវការឃុំខ្លួនបណ្តោះអាសន្ន ដោយបង្កើនការប្រើប្រាស់ជម្រើសទណ្ឌកម្មផ្សេងពីការឃុំខ្លួនសម្រាប់បទល្មើសមិនធ្ងន់ធ្ងរនៅទូទាំងប្រទេស។ ការផ្លាស់ប្តូរនេះ នឹងមិនត្រឹមតែកាត់បន្ថយភាពចង្អៀតណែន កាត់បន្ថយការចំណាយនៅក្នុងពន្ធនាគារ និងបង្កើនសមត្ថភាពមន្ត្រីពន្ធនាគារនៅក្នុងពន្ធនាគារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលមានទៅលើកុមារ ពេលណាដែលឪពុកម្តាយជាប់ពន្ធនាគារ ក៏ដូចជាអ្នកជាប់ពន្ធនាគារខ្លួនឯងផ្ទាល់ ក្រុមគ្រួសារ និងសហគមន៍។

ដូចដែលអង្គការ លីកាដូ បានបង្ហាញពីពេលមុន អត្រានៃស្ត្រី និងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការ គឺបច្ចុប្បន្នមានកម្រិតខ្ពស់ជាងចំនួនអត្រាអ្នកជាប់ឃុំបណ្តោះអាសន្នជាបុរស។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៤ ស្ត្រីចំនួន ៧០% នៅក្នុងពន្ធនាគារ គឺជាអ្នកជាប់ពន្ធនាគារបណ្តោះអាសន្នរង់ចាំសវនាការ រួមទាំងអ្នកដែលរង់ចាំសាលដីកាឧទ្ធរណ៍ ឬសាលដីកាស្ថាពរ។ នៅខណៈដែលអង្គការ លីកាដូ មិនមានទិន្នន័យទាក់ទងនឹងថាតើមានស្ត្រីចំនួនប៉ុន្មាននាក់ក្នុងចំណោមស្ត្រីទាំងនោះ មានភារកិច្ចមើលថែរក្សាកូន ចំនួននេះអាចនឹងមានកម្រិតខ្ពស់ ហើយអង្គការ លីកាដូ ជឿជាក់ថាស្ត្រីមួយចំនួនច្រើន អាចជៀសពីការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការបាន។

ទោះបីជាស្ត្រី ដែលត្រូវបានចោទប្រកាន់បទព្រហ្មទណ្ឌទាំងនោះ បន្ទាប់មកត្រូវបានរកឃើញកំហុសនៅក្នុងពេលសវនាការ និងផ្តន្ទាទោសជាប់ពន្ធនាគារក៏ដោយ ក៏ផលប៉ះពាល់អវិជ្ជមានលើកូនរបស់អ្នកទាំងនោះ នឹងមានការកាត់បន្ថយដែរ។ ក្នុងចំណោមបញ្ហាជាច្រើន គ្រួសារនឹងមានពេលវេលាក្នុងការរៀបចំការមើលថែរក្សាមួយដែលសមរម្យ និងការបញ្ជូនកូនចូលរៀន ប្រសិនបើកូននឹងត្រលប់ទៅផ្ទះវិញ។ កុមារនឹងមានការត្រៀមខ្លួនប្រសើរជាងនឹង សម្រាប់អំឡុងពេលនៅដាច់ពីម្តាយ ទាំងផ្លូវកាយ និងផ្លូវចិត្តរបស់កុមារ ហើយគ្រួសារនឹងមានបញ្ហា ផ្នែកហិរញ្ញវត្ថុតិចតួច។

អង្គការ លីកាដូ ជឿថាចំនួននៃស្ត្រីជាប់ពន្ធនាគារមួយចំនួនអាចនឹងលើកលែងការជាប់ពន្ធនាគារនៅពេលកាត់ទោស។ នៅក្នុងការស្ទាបស្ទង់មតិលើអ្នកជាប់ពន្ធនាគារជាស្ត្រីនីតិជនចំនួន ៤៧៩ នាក់ ឆ្នាំ២០១៤ អង្គការ លីកាដូ បានរកឃើញថា ច្រើនជាងមួយភាគបីត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសពីបទល្មើសពាក់ព័ន្ធនឹងគ្រឿងញៀន នៅខណៈដែល ៣១% ផ្សេងទៀត ត្រូវបានជាប់ពន្ធនាគារដោយសារបទល្មើសតូចតាច ដូចជាបទល្មើសលួច ទទួលផលចោរកម្ម រំលោភលើសេចក្តីទុកចិត្ត បំផ្លាញទ្រព្យសម្បត្តិ និងនេសាទខុសច្បាប់។ នៅក្នុងទស្សនៈរបស់អង្គការ លីកាដូ ដោយអង្គហេតុនៃបទល្មើសភាគច្រើន (ប្រសិនបើមិនមែនបទល្មើសទាំងអស់) មិនមានអំពើហិង្សា គួរតែមានការពិចារណាលើជម្រើសទណ្ឌកម្មផ្សេងទៀតដែលមិនចាំបាច់បំបែកអ្នកទាំងនោះពីក្រុមគ្រួសារ និងសហគមន៍របស់អ្នកទាំងនោះនោះទេ។

"ចំនួនស្ត្រីជាជនល្មើសមួយចំនួន មិនបានបង្កជាគ្រោះថ្នាក់ដល់សង្គមនោះទេ ហើយការឃុំខ្លួនអ្នកទាំងនោះក៏មិនបានជួយអ្វីដែរ ប៉ុន្តែបែរជាធ្វើឲ្យប៉ះពាល់ដល់ការធ្វើសមាហរណកម្មរបស់អ្នកទាំងនោះទៅក្នុងសង្គមវិញ... ដោយទុកស្ត្រីទាំងនោះនៅក្រៅពន្ធនាគារ នៅពេលដែលការឃុំខ្លួនមិនលក្ខណៈមិនចាំបាច់ ឬមិនសមហេតុផល កូនរបស់អ្នកទាំងនោះ អាចនឹងត្រូវបានជួយសង្គ្រោះពីការទទួលរងផលអវិជ្ជមានពីការឃុំខ្លួនម្តាយរបស់ពួកគេ រួមទាំងការដាក់ក្មេងឲ្យរស់នៅក្រោមអាណាព្យាបាល និងការរស់នៅក្នុងពន្ធនាគារទៅពេលអនាគត"

វិធានទីក្រុងបាងកក, បទអត្ថាធិប្បាយចំពោះវិធាន ៥៧-៥៨

# ថែរក្សាចំណងទំនាក់ទំនងរវាងម្តាយ និងកូន

អង្គការ លីកាដូ ជឿថា ម្តាយជាច្រើន គួរតែអាចត្រូវបានលើកលែងការជាប់នៅក្នុងពន្ធនាគារ ទោះជាមានករណីច្បាស់លាស់មួយចំនួនដែលពេលវេលាជាប់នៅក្នុងពន្ធនាគារ អាចជាជម្រើសល្អបំផុតមួយ។ នៅក្នុងករណីទាំងនេះ អង្គការ លីកាដូ សំណូមពរដល់អាជ្ញាធរពន្ធនាគារ សូមមេត្តាធ្វើការផ្លាស់ប្តូរជាមូលដ្ឋានលើប្រព័ន្ធនៃការមកសួរសុខទុក្ខនៅក្នុងពន្ធនាគារជាបន្ទាន់ ដូចនេះកុមារអាចនឹងមកសួរសុខទុក្ខម្តាយរបស់អ្នកទាំងនោះដោយងាយស្រួល ហើយលក្ខខណ្ឌនៃការជួបមានភាពប្រសើរឡើង ដែលអនុញ្ញាតឲ្យមានការបន្តរីកចម្រើនជាវិជ្ជមាននូវទំនាក់ទំនងរវាងម្តាយ និងកូន។

"កូនខ្ញុំដែលមានអាយុ ៣ឆ្នាំ នាងយំរាល់យប់ដោយនាងមិនដែលទទួលទានដំណេកក្បែរនាក់ណាម្នាក់ក្រៅពីខ្ញុំទេ។ នាងមិនទទួលទានអាហារ ឬទឹកអ្វីទាំងអស់ ហើយតែងតែយំទាររកខ្ញុំជានិច្ច។"

ជាជំហានទីមួយអាជ្ញាធរគួរតែលើកលែងការយកប្រាក់កម្រៃនានា សម្រាប់ការមកសួរសុខទុក្ខអ្នកជាប់ពន្ធនាគារ។ ជាគោលការណ៍ វិធានការនេះ គួរតែត្រូវបានអនុវត្តគ្រប់អ្នកមកសួរសុខទុក្ខទាំងអស់ ប៉ុន្តែគួរតែត្រូវបានអនុវត្តភ្លាមៗជាអាទិភាព ទៅលើការមកសួរសុខទុក្ខរបស់កូនអ្នកជាប់ពន្ធនាគារ។ បន្ទាប់មក រយៈពេល និងភាពញឹកញាប់នៃការមកសួរសុខទុក្ខរបស់គ្រួសារ ជាពិសេសការជួបជុំរវាងម្តាយ និងកូន គួរតែមិនគួរមានភាពតឹងរឹងនោះទេ។ ផ្ទុយទៅវិញ អាជ្ញាធរពន្ធនាគារ គួរតែពិចារណាអនុញ្ញាតឲ្យមានការជួបរយៈពេលកន្លះថ្ងៃ ឬពេញមួយខែរវាងម្តាយ និងកូន ជាពិសេសថ្ងៃចុងសប្តាហ៍ ឬថ្ងៃឈប់សំរាកពីការ សិក្សា ដើម្បីកាត់បន្ថយការរំខានពីសកម្មភាពប្រចាំថ្ងៃរបស់កុមារ។ ការរៀបចំបែបនេះ នឹងផ្តល់ប្រយោជន៍ជាពិសេសដល់ក្រុមគ្រួសារ ដែលត្រូវធ្វើដំណើរផ្លូវឆ្ងាយ ដើម្បីមកជួបសួរសុខទុក្ខ និងអ្នកដែលមិនអាចមកសួរសុខទុក្ខជាទៀងទាត់។

ជាការសំខាន់ ការជួបសួរសុខទុក្ខរវាងម្តាយ និងកូន គួរតែត្រូវបានអនុញ្ញាត ជាការជួបផ្ទាល់ផ្នែករូបរាងកាយ និងត្រូវបានធ្វើឡើងក្នុងស្ថានភាពដែលមានភាពឯកជន និងនៅក្នុងបរិយាកាសធម្មជាតិឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ម្តាយ គួរតែមិនត្រូវបានដាក់ឲ្យចេញពីកូនដោយរបាំងដែក ឬមើលគ្នាតាមកញ្ចក់នោះទេ ហើយបរិយាកាសនៅជុំវិញកន្លែងជួបគ្នា មិនគួរផ្អែកលើស្ថានភាពហិរញ្ញវត្ថុនោះទេ។ ម្តាយគួរតែត្រូវបានអនុញ្ញាតឲ្យនិយាយជាមួយកូនរបស់អ្នកទាំងនោះ តាមទូរស័ព្ទជាទៀងទាត់ សម្រាប់ពេលវេលាសមរម្យណាមួយ និងគួរតែមិនត្រូវបានហាមឃាត់ពីការធ្វើបែបនេះដោយផ្អែកលើកត្តាហិរញ្ញវត្ថុនោះទេ។ នេះជាការសំខាន់ណាស់សម្រាប់អ្នកដែលមានក្រុមគ្រួសាររស់នៅឆ្ងាយ ឬមិនអាចមកសួរសុខទុក្ខជាទៀងទាត់។



កូនតូច និងអនាព្យាបាល ខែមីនា ឆ្នាំ២០១៥

នៅក្នុងរយៈវែង អាជ្ញាធរពន្ធនាគារ គួរតែពិចារណារៀបចំប្រព័ន្ធមួយ ដើម្បីអនុញ្ញាតឲ្យម្តាយអាចទៅលេងកូនរបស់អ្នកទាំងនោះបាននៅឯផ្ទះសម្រាប់រយៈពេលខ្លីមួយ ប្រសិនបើមានសុវត្ថិភាព និងសមរម្យ។ ជាការសាកល្បងប្រព័ន្ធនេះអាចអនុវត្តចំពោះម្តាយណាដែលជិតផុតរយៈពេលទទួលទោសជាប់ពន្ធនាគារ របស់អ្នកទាំងនោះ។ ការរៀបចំបែបនេះ នឹងអនុញ្ញាតឲ្យម្តាយ និងកូនចាប់ផ្តើមបង្កើតទំនាក់ទំនងឡើងវិញ នៅក្នុងស្ថានភាពរបស់អ្នកទាំងនោះ ដោយអនុញ្ញាតឲ្យម្តាយចាប់ផ្តើមដំណើរការនៃការសម្របខ្លួន ទាំងផ្លូវកាយ និងផ្លូវចិត្ត ទៅនឹងជីវិតបន្ទាប់ពីជាប់ក្នុងពន្ធនាគារ ហើយនឹងជួយឲ្យអ្នកទាំងនោះធ្វើសមាហរណកម្មទៅក្នុងក្រុមគ្រួសារ និងសហគមន៍របស់អ្នកទាំងនោះវិញ។

នៅអំឡុងពេលជួបសួរសុខទុក្ខ មន្ត្រីពន្ធនាគារអាចធ្វើកិច្ចការច្រើនជាងនេះ ដើម្បីធានាថា បទពិសោធន៍របស់កុមារចំពោះការទៅសួរសុខទុក្ខម្តាយរបស់អ្នកទាំងនោះនៅក្នុងពន្ធនាគារ ជាបទពិសោធន៍វិជ្ជមាន។ ឧទាហរណ៍៖ ប្រសិនបើពួកគេអាចជ្រើសរើសបាន ឬបើអាចធ្វើទៅរួច ទីកន្លែងជួបសួរសុខទុក្ខម្តាយ គួរតែត្រូវបានអនុញ្ញាតឲ្យស្លៀកពាក់ខោអាវផ្ទាល់ខ្លួនរបស់អ្នកទាំងនោះ នៅពេលពួកគេជួបជាមួយកូន ហើយអ្នកជាប់ពន្ធនាគារបណ្តោះអាសន្នរង់ចាំសវនាការ មិនគួរស្លៀកពាក់ឯកសណ្ឋានពណ៌ខៀវដែលជាឯកសណ្ឋានសម្រាប់អ្នកជាប់ពិរុទ្ធនោះទេ។ ក្រៅពីការរៀបចំសន្តិសុខសំខាន់ៗ ការជួបសួរសុខទុក្ខរបស់កុមារ មិនគួរទៅជួបមន្ត្រីពន្ធនាគារច្រើនជាងការចាំបាច់នោះទេ ហើយម្តាយរបស់អ្នកទាំងនោះ គួរតែអាចចូលក្នុង និងចាកចេញពីទីកន្លែងជួបសួរសុខទុក្ខ ដោយមិនចាំបាច់អមដំណើរដោយអ្នកយាមនោះទេ។ ប្រសិនបើកុមារ ឬនីតិជន ដែលអមដំណើរជាមួយ ត្រូវបានគេឆែកឆេរមុនពេលអ្នកទាំងនោះ អាចជួបសួរសុខទុក្ខ សកម្មភាពនេះគួរតែត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្ន និងក្នុងលក្ខណៈសមរម្យ។

ជាជាងកម្រិតការជួបជុំ នៅកន្លែងជួបជុំតូចចង្អៀតក្នុងតំបន់នៅក្នុងពន្ធនាគារណាដែលមានសល់កន្លែងទំនេរ មន្ត្រីពន្ធនាគារ គួរតែរៀបចំសម្រាប់កុមារជួបម្តាយរបស់អ្នកទាំងនោះ នៅក្នុងបរិវេណដែលធំ ជាកន្លែងដែលកុមារអាចមានអារម្មណ៍ស្រួលខ្លួន និងអាចលេងជាមួយម្តាយរបស់អ្នកទាំងនោះទៀតផង។ ប្រភេទនៃការរៀបចំពិសេសនេះ គឺមានសារសំខាន់នៅពេលដែលពិចារណាចំពោះការភ្ជាប់ទំនាក់ទំនងរវាងបងប្អូនបង្កើត ប្រសិនបើម្នាក់អ្នកណាម្នាក់រស់នៅក្នុងពន្ធនាគារជាមួយម្តាយ។

## ការបែកបាក់គ្រួសារ

### ចិន្តា

ចិន្តា ស្វាមីរបស់នាង និងកូនប្រាំនាក់របស់អ្នកទាំងពីរ មិនដែលមានផ្ទះជាអចិន្ត្រៃយ៍ផ្ទាល់ខ្លួននោះទេ។ ផ្ទុយទៅវិញ អ្នកទាំងអស់គ្នាបានផ្លាស់ទីលំនៅពីកន្លែងមួយទៅកន្លែងមួយ ដើម្បីរកការងារធ្វើ។ ពួកគេបានប្រាប់អង្គការ លីកាដូ ថាថ្មីៗនេះពួកគេត្រូវបានគេឲ្យដីមួយកន្លែង ប៉ុន្តែភ្លាមៗត្រូវបានគេបណ្តេញចេញ និងចោទប្រកាន់ពីបទទន្ទ្រានដីកាន់កាប់ខុសច្បាប់។

នៅពេលនគរបាលបានមកបំផ្លាញផ្ទះសម្បែងរបស់ពួកគាត់ ស្វាមីរបស់ចិន្តា និងកូនប្រុសច្បង បានរត់ទៅពួននៅព្រៃក្បែរនោះ ហើយកូនៗផ្សេងៗទៀតដែលមានអាយុ ១៣, ១០, ៧ និង៤ឆ្នាំ បានរត់ទៅផ្ទះអ្នកជិតខាង។ រីឯចិន្តាវិញ ត្រូវបានចាប់ខ្លួន និងបញ្ជូនខ្លួនទៅកាន់ប៉ុស្តិ៍នគរបាលក្នុងតំបន់ ហើយឥឡូវនាងស្ថិតនៅក្នុងពន្ធនាគារ។ នគរបាលមិនបានសួរនាំនាងថាតើនាងមានកូនឬគ្មាននោះទេ។

នៅពេលដែលអង្គការ លីកាដូ បានជួបនឹងចិន្តា នាងមិនបានដឹងថាកូនៗរបស់នាងកំពុងនៅទីណានោះទេ។ ទូរស័ព្ទរបស់ស្វាមីនាង ត្រូវបានគេរឹបអូសអំឡុងពេលបណ្តេញចេញ ហើយរហូតដល់មួយខែក្រោយមក ទើបស្វាមីរបស់ចិន្តាអាចទិញទូរស័ព្ទថ្មីមួយវិញ ដូចនេះនាងអាចទូរស័ព្ទទៅគាត់បាន។ ឥឡូវនាងអាចនិយាយជាមួយស្វាមីម្តងម្កាល នៅពេលនាងអាចមានលទ្ធភាពប៉ុណ្ណោះ។

ស្វាមីនាង ធ្លាប់មកជួបសួរសុខទុក្ខនាងជាមួយកូនពីរនាក់តែម្តងគត់ បន្ទាប់ពីចិន្តាត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យដោយការឈឺពោះធ្ងន់ធ្ងរ។

ចិន្តាបានប្រាប់អង្គការ លីកាដូ ថា"ប្រសិនបើគាត់មានប្រាក់ ខ្ញុំនឹងសុំឲ្យគាត់ទិញអាហារសម្រាប់កូនៗរបស់យើង។ គាត់គួរតែចំណាយទៅលើអ្នកទាំងនោះ មិនគួរចំណាយមកសួរសុខទុក្ខខ្ញុំនៅក្នុងពន្ធនាគារនោះទេ។"

អង្គការ លីកាដូ បានជួបនឹងក្រុមគ្រួសាររបស់ចិន្តាភ្លាមៗ បន្ទាប់ពីជួបនាងនៅក្នុងពន្ធនាគារ ហើយក៏បានប្រាប់នាងអំពីទីកន្លែងដែលអ្នកទាំងនោះរស់នៅ និងស្ថានភាពជីវភាពរបស់អ្នកទាំងនោះ។ ដោយមិនមានកន្លែងសម្រាប់ទទួលទានដំណេក និងភ័យខ្លាចត្រូវគេចាប់ខ្លួន ស្វាមីរបស់នាងបានរត់ជាមួយកូនៗរបស់នាងទៅខេត្តក្បែរខាង ជាកន្លែងដែលក្រុមគ្រួសារនឹងត្រូវស្នាក់នៅបណ្តោះអាសន្ននៅក្នុងផ្ទះអ្នកស្គាល់គ្នា។ ចាប់តាំងពីមានការចាប់ខ្លួននាង កូនប្រុសពៅរបស់នាងមានស្ថានភាពសុខភាពមិនល្អ ហើយបានចូលមន្ទីរពេទ្យមួយរយៈខ្លី។ ចិន្តា ត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នរង់ចាំសនាការ មុនពេលថ្ងៃចូលឆ្នាំថ្មី នៅខែមេសា ឆ្នាំ២០១៥។

---

### នារី

នារី មានកូនបីនាក់ ប្រុសពីរនាក់ដោយម្នាក់អាយុ ៧ និងម្នាក់ទៀត ៤ ឆ្នាំ ហើយនិងកូនស្រីអាយុ ៧ខែ។ នាងត្រូវបានចាប់ខ្លួនកាលពីខែវិច្ឆិកា ឆ្នាំ២០១៤ និងចោទប្រកាន់ពីបទជួញដូរគ្រឿងញៀន។

មុនពេលមានការចាប់ខ្លួន គ្រួសាររបស់នារីបានរស់នៅជាមួយនឹងបងប្អូនរបស់នាងម្នាក់។ ពួកគេបានរស់នៅដោយប្រមូល និងលក់សំបកដប និងកំប៉ុងតាមដងផ្លូវ។ នៅពេលនាងនៅក្នុងពន្ធនាគារ ក្រុមគ្រួសាររបស់នាងបានរស់នៅបែកគ្នា។ ស្វាមីរបស់នាង ដែលលែងរស់នៅជាមួយបងប្អូននាង បានទៅរស់នៅតាមផ្លូវជាមួយកូនប្រុសអាយុ៤ឆ្នាំ ហើយកូនស្រីពៅបានទៅរស់នៅជាមួយម្តាយនៅក្នុងពន្ធនាគារ។កូនប្រុសច្បង ដែលធ្លាប់រស់នៅតាមដងផ្លូវ ត្រូវបានសុំឲ្យទៅនៅជាមួយបងប្អូនមួយទៀតជាបណ្តោះអាសន្ន។ កូនប្រុសនេះលែងទៅរៀនទៀតហើយ។

នៅពេលអង្គការ លីកាដូ បានជួបស្វាមីនារី គាត់កំពុងនៅជាមួយកូនប្រុសពៅនៅខាងក្រោមស្ពាន និងទើបតែជាពីការពុលអាហារ។ អ្នករត់ម៉ូតូឌុបនៅក្បែរនោះបានឲ្យម្ហូបអាហារ និងកន្លែងស្នាក់នៅមួយយប់ដល់គាត់នៅពេលគាត់ឈឺ។ ទោះបីជាមានធនធានតិចតួចក៏ដោយ ក៏ស្វាមីនារីនៅតែទៅជួបសួរសុខទុក្ខនាងនៅក្នុងពន្ធនាគារជាច្រើនដងជារៀងរាល់សប្តាហ៍ ហើយព្រោះតែស្ថានភាពគ្រួសាររបស់អ្នកទាំងពីរ ឆ្មាំពន្ធនាគារក៏បានអនុញ្ញាតឲ្យអ្នកទាំងពីរជួបគ្នាដោយមិនចាំបាច់បង់ថ្លៃជួបសួរសុខទុក្ខក្នុងពន្ធនាគារ។

នៅពេលនារី ត្រូវបានចាប់ខ្លួន នគរបាលមិនបានសួរនាងអំពីស្ថានភាពក្រុមគ្រួសាររបស់នាងទេ ហើយពេលដែលនាងត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារ ក៏មិនមានការនិយាយប្រាប់អំពីអ្វីនឹងកើតមានឡើងទៅលើកូនៗរបស់នាងឡើយ។ នាងមិនមានមេធាវី ហើយគ្រួសាររបស់នាងមិនមានអ្នកជួយទំនុកបំរុងនោះទេ។ អង្គការ លីកាដូ បានរៀបចំមេធាវីអង្គការមិនមែនរដ្ឋាភិបាលសម្រាប់នាង និងផ្តល់នូវការគាំទ្រផ្នែកសម្ភារៈមួយចំនួនសម្រាប់នាង និងកូនស្រីពៅរបស់នាងនៅក្នុងពន្ធនាគារ។ នៅថ្ងៃទី៣០ ខែមិនា ឆ្នាំ២០១៥ នាងបានទៅចូលរួមសវនាការរបស់នាង ហើយត្រូវបានផ្តន្ទាទោសពន្ធនាគាររយៈពេល ២ឆ្នាំ។ ប៉ុន្តែ ភ្លាមៗនាងបានទទួលព្រះរាជទានលើកលែងទោសពីព្រះមហាក្សត្រ និងត្រូវបានដោះលែងនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៥។



ក្មេងស្រីអាយុ៣ឆ្នាំ ជាកូនរបស់អ្នកជាប់ឃុំក្នុងពន្ធនាគារ ខែមីនា ២០១៥

# សេចក្តីបញ្ចប់

នៅក្នុងការបោះពុម្ពរបាយការណ៍ស្តីពី "រឿងរ៉ាវរបស់តារា" អង្គការ លីកាដូ បានសង្ឃឹមថាអគ្គនាយកដ្ឋានពន្ធនាគារ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងបោះជំហានទៅមុខមួយជំហានក្នុងការស្វែងយល់ឲ្យកាន់តែប្រសើរ និងដោះស្រាយបញ្ហាស្ថានភាពកុមារ រស់នៅក្នុងពន្ធនាគារជាមួយ ម្តាយរបស់អ្នកទាំងនោះ ដើម្បីធានាថា ទាំងសិទ្ធិរបស់ម្តាយ និងកុមារ ត្រូវបាន គោរពយ៉ាងពេញលេញ។ នាពេលនោះអង្គការ លីកាដូមិនដែលគិតថាត្រឹមតែរយៈពេល ២ខែ បន្ទាប់ពីរបាយការណ៍ត្រូវបានចេញ ចំនួនស្ត្រីមានផ្ទៃពោះ និងកុមារនៅក្នុងពន្ធនាគារមានការថយចុះ ៩០%។

នៅពេលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន អន្តរាគមន៍លើបញ្ហានេះ លោកបានអំពាវនាវជាពិសេសឲ្យមានការបញ្ឈប់ "វប្បធម៌មានកូនក្មេងរស់នៅជាមួយម្តាយនៅក្នុងពន្ធនាគារ" ដោយបានបន្ថែមថា "យើងមិនអនុញ្ញាតឲ្យស្ត្រីណាម្នាក់ដែលមានកូន ឬមានផ្ទៃពោះមាននៅក្នុងពន្ធនាគារតទៅទៀតទេ"។ ឥឡូវនេះជំហានដំបូងនៃការដោះលែងត្រូវបានបញ្ចប់ តែនៅតែមិនមានភាពច្បាស់លាស់ ថាតើអាជ្ញាធរកម្ពុជានឹងមានផែនការយ៉ាងណា ក្នុងការដោះស្រាយបញ្ហានេះនៅក្នុងរយៈពេលវែង។

អង្គការ លីកាដូ ទទួលស្គាល់ថា មានករណីមួយចំនួនដែលត្រូវតែធ្វើការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ និងផ្តន្ទាទោសពន្ធនាគារ ហើយទាំងនេះនឹងមិនអាចគេចផុតចំពោះម្តាយ និងស្ត្រីមានផ្ទៃពោះមួយចំនួននោះទេ។ អង្គការ លីកាដូ ក៏ទទួលស្គាល់ថា នៅករណីមួយចំនួនតូច មិនមានជម្រើសផ្សេងដែលស្ថិតស្ថេរ និងមានសុវត្ថិភាពសម្រាប់កូនរបស់ស្ត្រីទាំងនេះនោះទេ ហើយដូចនេះវាអាចជាប្រយោជន៍យ៉ាងខ្លាំង ប្រសិនបើកុមារទាំងនោះស្នាក់នៅជាមួយម្តាយរបស់ពួកគេនៅក្នុងពន្ធនាគារ។

ហេតុដូចនេះ អង្គការ លីកាដូ មិនដែលធ្វើការតស៊ូមតិស្នើសុំឲ្យបញ្ឈប់ទាំងស្រុង ការអនុញ្ញាតឲ្យកុមាររស់នៅជាមួយម្តាយរបស់អ្នកទាំងនោះនៅក្នុងពន្ធនាគារនោះទេ ដោយសារវាមានសុវត្ថិភាព និងសមរម្យសម្រាប់កុមារតូចៗទាំងនោះ។ ផ្ទុយទៅវិញ អង្គការ លីកាដូ តែងតែសំណូមពរឲ្យមានការវាយតម្លៃជាបន្តបន្ទាប់ និងពេញលេញ ទៅលើករណីនីមួយៗ ដូចនេះការសម្រេចចិត្ត អាចត្រូវបានធ្វើឡើងដោយផ្អែកលើផលប្រយោជន៍ច្រើនបំផុតរបស់កុមារ។ នៅក្នុងករណីទាំងនោះ ដែលមិនមានជម្រើសផ្សេង អាជ្ញាធរពន្ធនាគារអាចធ្វើឲ្យមានការផ្លាស់ប្តូរ ដោយជួយសម្រាលផលប៉ះពាល់អវិជ្ជមាននានា។

ជំនួសឲ្យការរៀបចំជាពិសេស គួរតែមានវិធីសាស្ត្រទូលំទូលាយ និងរយៈពេលយូរ ដែលអាចដោះស្រាយបញ្ហាតាំងពីចំនុចឫសគល់ គឺចាប់តាំងពីមុនពេលដែលស្ត្រីដែលមានផ្ទៃពោះ និងកុមារចូលទៅក្នុងពន្ធនាគារ។ ករណីនីមួយៗ គួរតែត្រូវបានពិចារណាលើអង្គហេតុ និងគួរតែពិចារណា លើបុគ្គលិកលក្ខណៈរបស់ម្តាយ ស្ថានភាពគ្រួសារ និងប្រយោជន៍ច្រើនបំផុតរបស់កុមារ។ គោលការណ៍ដូចគ្នាទាំងនេះ គួរតែត្រូវបានអនុវត្តទៅលើគ្រប់ស្ត្រីទាំងអស់ដែលមានកូនរស់នៅជាមួយ និងដែលត្រូវបានចោទប្រកាន់ពីបទល្មើសតូចតាច និងមិនត្រឹមតែអ្នកដែលមានកូនរស់នៅជាមួយក្នុងពន្ធនាគាររួចទៅហើយនោះទេ។

ការវិវឌ្ឍន៍ថ្មីៗ ក្នុងការកាត់បន្ថយចំនួនកុមារនៅក្នុងពន្ធនាគារត្រូវបានធ្វើឡើង ដើម្បីការពារកុមារពីការទទួលរងទុក្ខនៅថ្ងៃអនាគត។ ប៉ុន្តែ អង្គការ លីកាដូ ជឿថា អ្នកជាប់ពន្ធនាគារជាច្រើនអាចនឹងត្រូវរួចផុតពីការរងទុក្ខទាំងនោះតាំងពីពេលដំបូង។ ដោយពិចារណាព័ត៌មានលំអិតរបស់ស្ត្រីដែលមានឈ្មោះក្នុងការទទួលបានព្រះរាជទានលើកលែងទោស អង្គការ លីកាដូ សន្និដ្ឋានថា អ្នកជាប់

ពន្ធនាគារជាច្រើនទៀត គួរតែអាចជាបេក្ខជនគ្រប់លក្ខខណ្ឌក្នុងការទទួលបានការដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន និងដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ឬទោសដែលមិនចាំបាច់ជាប់នៅក្នុងពន្ធនាគារ និង មិនគួរត្រូវបានដាក់នៅក្នុងពន្ធនាគារនោះទេ។

ដោយគិតទៅអនាគត និងដើម្បីបំបាត់ការរងទុក្ខរបស់កុមារជាច្រើននាក់ អង្គការ លីកាដូ សំណូមពរដល់អាជ្ញាធរនានា សូមលោកមេត្តាពិចារណា លើផលប៉ះពាល់នៃការជាប់ពន្ធនាគាររបស់ម្ដាយ ទៅលើកូនរបស់អ្នកទាំងនោះដែលរស់នៅក្រៅពន្ធនាគារ និងផ្ដល់ការយកចិត្តទុកដាក់ខ្លាំងបំផុត លើជម្រើសទោសផ្សេងក្រៅពីការដាក់ពន្ធនាគារសម្រាប់ក្រុមមនុស្សអាទិភាពនេះ។ ការធ្វើបែបនេះធ្វើឲ្យអាជ្ញាធរទាំងនោះ អាចធ្វើឲ្យកុមារជាច្រើនបន្តរស់នៅជាមួយម្ដាយ ថែរក្សាចំណងគ្រួសារ និងការពារឱកាសរបស់កុមារក្នុងការទទួលបានការអប់រំ។ ប្រសិនបើមិនមានវិធានការជាជម្រើសផ្សេងបែបនេះទេ កុមារជាច្រើនពាន់នាក់នៅទូទាំងប្រទេសកម្ពុជា នឹងបន្តទទួលរងទុក្ខលំបាកយ៉ាងខ្លាំងពីគោលការណ៍ឃុំខ្លួនម្ដាយ ដោយមិនចាំបាច់នានា។

## អនុសាសន៍

**<u>ការចាប់ និងឃុំខ្លួន</u>**

នៅពេលណាដែលអាជ្ញាធរធ្វើការចាប់ខ្លួន និងឃុំខ្លួនស្ត្រី អាជ្ញាធរទាំងនោះគួរតែ៖

►►►ពិនិត្យមើល ថាតើស្ត្រីដែលចាប់ទាំងនោះមានកូនរស់នៅជាមួយឬទេ និងអនុញ្ញាតឲ្យស្ត្រីទាំងនោះរៀបចំការថែរក្សាដែលមានសុវត្ថិភាពដល់កូនរបស់អ្នកទាំងនោះមុនពេលយកពួកគេទៅកាន់មន្ទីរឃុំឃាំង

►►► ពិចារណា ថាតើមានសារសំខាន់ខ្លាំងឬទេក្នុងការប្រើប្រាស់ស៊ីរ៉ែន ឬដាក់ខ្នោះដៃម្ដាយនៅមុខកូនរបស់អ្នកទាំងនោះ និងធានាថាការឆែកឆេរផ្ទះ និងខ្លួនប្រាណ ត្រូវបានធ្វើឡើងដោយមានការគោរព និងដោយពិចារណាពីវត្តមានរបស់កុមារ

►►► ពិចារណាពីផលប៉ះពាល់លើកុមារ មុនពេលធ្វើការចាប់ខ្លួន ដោយពិចារណាថាតើអាចនឹងមានវត្តមានរបស់កុមារ និងក្មេងវ័យជំទង់ដែរឬទេ ពេលវេលា និងវិធីសាស្ត្រនៃការចាប់ខ្លួន រួមមានថាតើការចាប់ខ្លួនគួរតែធ្វើឡើងនៅពេលភ្លឺ ឬយ៉ាងណា

►►► ប្រសិបើកុមារមានវត្តមាននៅពេលចាប់ខ្លួន សូមមេត្តាអនុញ្ញាតឲ្យម្ដាយរបស់អ្នកទាំងនោះ ពន្យល់អ្វីដែលកំពុងកើតឡើង ហើយប្រាប់ថាតើនាងនឹងត្រូវទៅកន្លែងណា។ ប្រសិនបើមិនអាច នគរបាលផ្ទាល់គួរតែពន្យល់ឲ្យបានច្បាស់លាស់។ ប្រសិនបើកុមារមិនមានវត្តមាន ត្រូវធានាថាអ្នកទាំងនោះទទួលបានការពន្យល់ពេលក្រោយ។

►►► ផ្ដល់ដល់ម្ដាយ នូវឱកាសទាក់ទងជាមួយកូនរបស់អ្នកទាំងនោះ និងអ្នកមើលថែរក្សាកូនរបស់អ្នកទាំងនោះដោយមិនពន្យាពេល។

►►► ធានាថា កំណត់ត្រានៃការចាប់ខ្លួន មានកត់ត្រានូវព័ត៌មានលំអិតអំពីកូនរបស់ជនសង្ស័យ អាយុរបស់អ្នកទាំងនោះ ទីកន្លែង ឈ្មោះ និង ព័ត៌មានទំនាក់ទំនងសម្រាប់អ្នកមើលថែរក្សាកូនរបស់អ្នកទាំងនោះ ប្រសិនបើម្ដាយយល់ព្រមផ្ដល់ព័ត៌មានទាំងនោះ។

**<u>ការសម្រេចចិត្តដាក់ឲ្យនៅជាប់ឃុំខ្លួនបណ្ដោះអាសន្ន សវនាការ និងការផ្ដន្ទាទោស</u>**

នៅពេលអាជ្ញាធរតុលាការ កំពុងធ្វើការសម្រេចចិត្តទៅលើការដាក់ស្ត្រីម្នាក់ ឲ្យជាប់ឃុំបណ្ដោះអាសន្នរង់ចាំសវនាការ ឬផ្ដន្ទាទោស អាជ្ញាធរទាំងនោះគួរតែ៖

►►► ធានាថា អ្នកទាំងនោះមានព័ត៌មានទាំងអស់ដែលមាន និងពាក់ព័ន្ធនឹងជនជាប់ចោទ រួមមានថាតើនាងមានផ្ទៃពោះ ឬមានកូនរស់នៅជាមួយឬទេ

►►► ពិចារណា ថាតើការឃុំខ្លួន គឺពិតជាចាំបាច់ឬទេ ពិចារណាពីអង្គហេតុនៃបទល្មើស បុគ្គលិកលក្ខណៈរបស់ម្ដាយ ស្ថានភាពគ្រួសាររបស់នាង និងការទទួលខុសត្រូវលើការថែរក្សា

►►► ពិចារណា លើផលប៉ះពាល់នៃការជាប់ពន្ធនាគារដែលអាចមានលើកូនរបស់ម្ដាយ រួមមានសុខុមាលភាព និងភាពអាចកើតមានឡើងនៃបទល្មើសនាពេលអនាគតរបស់កុមារទាំងនោះ

►►► ធានាថាការឃុំខ្លួនបណ្ដោះអាសន្នរបស់ស្ត្រីទាំងនោះ ត្រូវបានប្រើប្រាស់តែនៅពេលចាំបាច់បំផុត ហើយទម្រង់នៃការឃុំខ្លួនបណ្ដោះអាសន្នឆ្នាំ ២០១៤ ត្រូវបានប្រើប្រាស់ឲ្យបានត្រឹមត្រូវ ដោយពន្យល់ឲ្យបានច្បាស់លាស់ ថាតើមូលហេតុណាមួយក្នុងចំណោមមូលហេតុចំនួន ៦ ត្រូវបានប្រើប្រាស់លើករណីនេះ និងមានហេតុផលសមរម្យសម្រាប់គាំទ្រការធ្វើការសម្រេចចិត្តដាក់ឲ្យជាប់ឃុំបណ្ដោះអាសន្នរង់ចាំសវនាការ

►►► កំណត់នូវស្ត្រីមានផ្ទៃពោះ ឬស្ត្រីដែលមានកូនរស់នៅជាមួយ ទាំងនៅក្នុង និងក្រៅពន្ធនាគារ ដែលជាបេក្ខជនសមរម្យសម្រាប់ទោស

មិនជាប់ពន្ធនាគារ

►►► ប្រសិនបើចាំបាច់ អនុញ្ញាតឲ្យម្តាយមានពេលរៀបចំការមើលថែរក្សាកូនជំនួសខ្លួននៅចន្លោះពេលនៃការផ្តន្ទាទោស និងពេលចាប់ផ្តើមជាប់ពន្ធនាគាររបស់នាង

►►► ផ្តល់ដល់ក្រុមគ្រួសារ នូវព័ត៌មានអំពីសវនាការ ដើម្បីឲ្យកូនមានឱកាសស្វែងយល់ឲ្យកាន់តែច្បាស់នូវអ្វីដែលកំពុងកើតឡើងលើម្តាយរបស់អ្នកទាំងនោះ

**<u>ម្តាយនៅក្នុងពន្ធនាគារ</u>**

នៅពេលមានការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ឬដាក់ទោសឃុំខ្លួនក្នុងពន្ធនាគារ អាជ្ញាធរពន្ធនាគារ និងក្រសួងសង្គមកិច្ច គួរតែពិចារណានូវគ្រប់កត្តាទាំងអស់ខាងក្រោម៖

►►► រក្សាកំណត់ត្រាឲ្យបានច្បាស់លាស់របស់ម្តាយដែលមានកូននៅក្នុងបន្ទុក អាយុរបស់អ្នកទាំងនោះ ទីតាំង ឈ្មោះ និងព័ត៌មានទំនាក់ទំនងអ្នកមើលថែរក្សាចំបង ទៅតាមព័ត៌មានដែលមាន និងការអនុញ្ញាតពីម្តាយ

►►► លុបចោលការយកប្រាក់កម្រៃសម្រាប់កុមារដែល មកជួបសួរសុខទុក្ខម្តាយរបស់អ្នកទាំងនោះនៅក្នុងពន្ធនាគារ បន្ថែមពេលវេលាសម្រាប់អ្នកទាំងពីរជួបគ្នា និងអនុញ្ញាតឲ្យអ្នកទាំងពីរជួបគ្នាដោយផ្ទាល់ ជាលក្ខណៈឯកជនតាមដែលអាចធ្វើបាន និងស្លៀកសំលៀកបំពាក់ផ្ទាល់ខ្លួនរបស់ម្តាយប្រសិនបើអ្នកទាំងនោះចង់ស្លៀកពាក់

►►► ធានាថា ម្តាយអាចទូរស័ព្ទទៅកូនរបស់អ្នកទាំងនោះ និងសមាជិកគ្រួសារដទៃទៀតជាទៀងទាត់

►►► ខិតខំប្រឹងប្រែងក្នុងការជូនដំណឹងដល់ក្រុមគ្រួសារនូវ ព័ត៌មានសំខាន់ៗដូចជាកាលបរិច្ឆេទក្នុងនីតិវិធីតុលាការសំខាន់ៗ ការផ្លាស់ប្តូរទីកន្លែងឃុំខ្លួន និងបញ្ហាសុខភាព

►►► អនុញ្ញាតឲ្យម្តាយពិនិត្យមើលឡើងវិញនូវការរៀបចំការមើលថែរក្សាកុមារដែលត្រូវបានធ្វើឡើង នៅពេលមានការចាប់ខ្លួននិងផ្តល់ធនធានសម្រាប់ធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងការថែរក្សាកុមារ ដូចជាការផ្លាស់ប្តូរទីលំនៅ ឬ អ្នកថែរក្សាចម្បង។ កុមារផ្ទាល់គួរតែចូលរួមក្នុងការសម្រេចចិត្តទាំងនេះ

►►► គាំទ្រ និងជួយដល់អ្នកថែរក្សាកុមារចម្បង ដើម្បីឲ្យកុមារបន្តការសិក្សារបស់អ្នកទាំងនោះ និងទៅជួបសួរសុខទុក្ខម្តាយនៅក្នុងពន្ធនាគារជាទៀងទាត់ រួមមានការជួយក្នុងមធ្យោបាយធ្វើដំណើរ

►►► អនុញ្ញាតឲ្យម្តាយទៅសួរសុខទុក្ខកូនរបស់អ្នកទាំងនោះនៅឯផ្ទះ សម្រាប់រយៈពេលខ្លី ប្រសិនបើមានសុវត្ថិភាព និងសមរម្យជាពិសេស ម្តាយដែលនឹងជិតរួចទោសពន្ធនាគារ។

►►► ចាត់វិធានការពិសេស ដើម្បីអនុញ្ញាតឲ្យជនបរទេសធ្វើការទាក់ទងទៅកាន់ក្រុមគ្រួសារ និងអ្នកតំណាងទូតរបស់អ្នកទាំងនោះ

**<u>កុមារនៅក្នុងពន្ធនាគារ</u>**

នៅក្នុងករណីដែលម្តាយជាប់ក្នុងពន្ធនាគារ ហើយកុមារបន្តរស់នៅក្នុងពន្ធនាគារជាមួយម្តាយ អាជ្ញាធរពន្ធនាគារគួរតែ៖

►►► ផ្តល់ការវាយតម្លៃជាបុគ្គល និងបន្តបន្ទាប់នូវស្ថានភាពរបស់កុមារ ដោយពិចារណាទៅលើការផ្លាស់ប្តូរណាមួយនៅក្នុងពន្ធនាគារ និងតម្រូវការលូតលាស់របស់កុមារ រួមមានការធំធាត់របស់កុមារ សុខភាព ទំនាក់ទំនងជាមួយម្តាយ និងវត្តមានជម្រើសសមរម្យផ្សេងទៀត

►►► ធ្វើសកម្មភាពជាបន្ទាន់ ប្រសិនបើអាជ្ញាធរទាំងនោះដឹងថា មានស្ថានភាពនានាដែលកុមារនៅក្នុងពន្ធនាគារអាចនឹងជួបគ្រោះថ្នាក់ និង ផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីអំពីការលូតលាស់របស់កុមារ និងតម្រូវការថែទាំសុខភាពរបស់ម្តាយដែលមានផ្ទៃពោះ និងកុមារ

►►► ចេញនូវសេចក្តីណែនាំអំពីរបៀបរៀបចំ និងពង្រីកកន្លែងស្នាក់នៅខាងក្រៅ និងកន្លែងនឹងត្រូវដាក់កុមារដែលបានរស់នៅក្នុងពន្ធនាគារនៅពេលដែលអ្នកទាំងនោះមានអាយុលើសពីបីឆ្នាំ

►►► ធ្វើឲ្យកាន់តែប្រសើរឡើងនូវស្ថានភាពរបស់ស្ត្រីមានផ្ទៃពោះ និងកុមារដែលរស់នៅក្នុងពន្ធនាគារជាមួយម្តាយ ដូចនេះបរិយាកាសគឺសមរម្យសម្រាប់កុមារ និងមានសុវត្ថិភាព

►►►អនុញ្ញាតឲ្យមានទំនាក់ទំនងជាមួយសមាជិកក្រុមគ្រួសារដទៃទៀត ជាពិសេសបងប្អូនរបស់កុមារ ដោយរួមមានការទូរស័ព្ទជាទៀងទាត់ និងធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌសួរសុខទុក្ខ។

www.licadho-cambodia.org